ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-Nov-2010, 14:24
CMS/CFO: Kau Keoratanak

ករណីខ្វែងយោបល់គ្នាលេខ: ០០១/១៨-១១-២០០៨-អវតក/អបជ

ចំពោះមុខ:
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ី ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី១៧ ខែ សីហា ឆ្នាំ ២០០៩

---

ឧបសម្ព័ន្ធ I: សំណៅសាធារណៈ: មានការលុប

# សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង

---

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**ការិយាល័យរដ្ឋបាល**
តូនី ក្រាញ់
Khnut ROSANDHAUG

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម
Certified Copy/Copie Conforme
ថ្ងៃទី(On/Le)...18...ខែ(Month/Mois) August
ឆ្នាំ(Year/Année)...2009...
ក្រឡាបញ្ជីនាយក/Chief of Greffier..Chanrath

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

០០១/១៨-១១-២០០៨-អវតក/អបជ

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានទទួលយកនូវការខ្វែងយោបល់គ្នាមួយរវាងសហព្រះរាជអាជ្ញានៃអ.វ.ត.ក ដោយយោងតាមវិធានផ្ទៃក្នុង ៧១(២) ដែលសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរចំនួនពីរ បង្កើតបានជាសំណុំរឿងលេខ ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស និង ០០៤/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស ("ដីកាបញ្ជូនរឿងឲ្យស៊ើបសួរថ្មី") ដែលត្រូវបញ្ជូនទៅសហចៅក្រមស៊ើបអង្កេតសម្រាប់បើកការស៊ើបសួរ តែមិនត្រូវបានឯកភាពពីសហព្រះរាជអាជ្ញាជាតិ ("ការខ្វែងយោបល់")។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨ ការិយាល័យរដ្ឋបាល បានបញ្ជូនមកអង្គបុរេជំនុំជម្រះនូវឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នា ស្របតាមវិធាន ៧១(២) (អំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ) ដែលក្នុងនោះសហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា "គាត់មានបំណងចង់ដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីចំនួនពីរទៀត[...] និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទីពីរក្នុងសំណុំរឿង០០២"[១]។ សហព្រះរាជអាជ្ញាអន្តរជាតិស្នើថា "សារណាទាំងបី ត្រូវបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត សម្រាប់បើកការស៊ើបសួរ"[២]។ នៅក្នុងអំណះអំណាងរបស់គាត់ សហព្រះរាជអាជ្ញាអន្តរជាតិរាយការណ៍ថា សហព្រះរាជអាជ្ញាជាតិ "មានការខ្វែងយោបល់គ្នាក្នុងការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្ម ដែលបានចង្អុលបង្ហាញ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី និងជាលទ្ធផលបានបដិសេធក្នុងការចុះហត្ថលេខាលើរាល់សារណាបន្ថែមទាំងអស់"[៣]។

---

[១] ឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នា ស្របតាមវិធាន ៧១(២), ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ("អំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ"), កថាខណ្ឌទី២។

[២] អំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌទី១២០។

[៣] អំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌទី៥។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

២. សហព្រះរាជអាជ្ញាជាតិ បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នា ស្របតាមវិធាន ៧១(២) កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ") បន្ទាប់ពីអង្គបុរេជំនុំជម្រះបានយល់ព្រមតាមសំណើសុំពន្យារពេលក្នុងការដាក់ចម្លើយតបចំនួនពីរដងរួចមក[៤]។ ក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាជាតិ បានលើកឡើងអំពីមូលហេតុ ដែលគាត់មិនឯកភាពជាមួយនឹងដីកាបញ្ជូនរឿងឲ្យស៊ើបសួរថ្មី។

៣. កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានចេញដីកាអញ្ជើញដល់សហព្រះរាជអាជ្ញាឲ្យដាក់ជូនសេចក្តីសន្និដ្ឋានបន្ថែមទៀតប្រសិនបើមាន ដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីនៃករណីខ្វែងយោបល់គ្នា កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩[៥]។

៤. ក្នុងការឆ្លើយតបរបស់ខ្លួន កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិ បានជូនដំណឹងដល់អង្គបុរេជំនុំជម្រះថា "គាត់ពុំមានសេចក្តីសង្កេតបន្តទៀត ដែលជាការបន្ថែមទៅលើសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលមានរួចស្រេចហើយ នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលបានដាក់កាលពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៨ នោះឡើយ"[៦]។

៥. សហព្រះរាជអាជ្ញាជាតិបានដាក់ជូននូវឯកសារមួយសំណុំ ដែលពាក់ព័ន្ធទៅនឹងការពិភាក្សាដេញដោលនៅក្នុងរដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា និងការពិភាក្សារវាងមន្ត្រីអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្តីពីការបង្កើត អ.វ.ត.ក។

---

[៤] សេចក្តីសម្រេចលើសំណើសុំពន្យារពេលរបស់សហព្រះរាជអាជ្ញាដើម្បីដាក់ឯកសារឆ្លើយតប, ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ[illegible] និងសេចក្តីសម្រេចលើសំណើសុំពន្យារពេលបន្តរបស់សហព្រះរាជអាជ្ញាជាតិដើម្បីដាក់ឯកសារឆ្លើយតប, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ លេខ៦។

[៥] សេចក្តីអញ្ជើញសហព្រះរាជអាជ្ញាឲ្យដាក់សេចក្តីសន្និដ្ឋានបន្ថែម, ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារលេខ៨។

[៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងការអញ្ជើញរបស់អង្គបុរេជំនុំជម្រះឲ្យដាក់សេចក្តីសន្និដ្ឋានបន្តទៀត, ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារលេខ៩ កថាខណ្ឌទី២។

៦. តាមរយៈការជូនដំណឹងដែលបានដាក់ កាលពីថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៩[៧] សហព្រះរាជអាជ្ញាអន្តរជាតិបានដកចេញនូវសំណើរបស់ខ្លួន ដែលស្នើសុំឱ្យអង្គបុរេជំនុំជម្រះវិនិច្ឆ័យលើការខ្វែងយោបល់គ្នាចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក-ក.ស.ច.ស ដោយសារតែគាត់បានពេញចិត្តជាមួយនឹងភស្តុតាងដែលបញ្ជាក់ថា ជនសង្ស័យរូបនេះបានទទួលមរណភាព បន្ទាប់ពីមានការស៊ើបអង្កេតរួចមក។ សហព្រះរាជអាជ្ញាជាតិមិនបានឆ្លើយតបទៅនឹងការជូនដំណឹងនេះទេ។ ការដកចេញនូវការខ្វែងយោបល់គ្នាពាក់ព័ន្ធនឹងដីកាស៊ើបសួរបន្ថែម ត្រូវបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះកាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៩[៨]។

៧. កាលពីថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាជាតិបានដាក់ "សំណើសុំដាក់ឯកសារបន្ថែមពាក់ព័ន្ធទៅនឹងការពិភាក្សាដេញដោល នៅចំពោះមុខវង្គសភាជាតិ[៩]។ សហព្រះរាជ-អាជ្ញាអន្តរជាតិមិនបានជំទាស់ទៅនឹងសំណើសុំនេះទេ ទោះបីជាគាត់បានអះអាងថា ឯកសារទាំងនោះត្រូវបានដាក់យឺតពេលក៏ដោយ[១០]។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ឯកសារដែលសហព្រះរាជអាជ្ញាជាតិបានស្នើសុំដាក់ជូននោះ ទាក់ទងជាមួយ និងបំពេញនូវឯកសារផ្សេងទៀតដែលជាផ្នែកនៃករណីខ្វែងយោបល់គ្នារួចទៅហើយ និងសង្កេតឃើញថា សហព្រះរាជ-អាជ្ញាអន្តរជាតិ មានលទ្ធភាពក្នុងការផ្តល់យោបល់ទៅលើបញ្ហាទាំងនេះ។ ស្ថិតក្នុងកាលៈ-ទេសៈបែបនេះ និងបន្ទាប់ពីបានពិចារណាឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិ មិនជំទាស់ទេនោះ សំណើសុំនេះត្រូវបានយល់ព្រម។

---

[៧] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីការបញ្ចប់កិច្ចស៊ើបសួរនិងដំណើរការខ្វែងយោបល់គ្នាដែលពាក់ព័ន្ធ ឯកសារលេខ១១ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៩។

[៨] សេចក្តីណែនាំ របស់អង្គបុរេជំនុំជម្រះ ឱ្យដាក់ឯកសារពិស្តារបន្ថែមនិងនីកាកំណត់កាលបរិច្ឆេទ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៩ ឯកសារលេខ១៥ ("សេចក្តីណែនាំ") កថាខណ្ឌទី ៦-៧។

[៩] សំណើសុំរបស់ព្រះរាជអាជ្ញាជាតិសុំដាក់ឯកសារបន្ថែមនៅក្នុងចម្លើយតបទៅនឹងការអញ្ជើញរបស់អង្គបុរេជំនុំជម្រះអោយដាក់សេចក្តីសន្និដ្ឋានបន្ថែមទៀត, ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ឯកសារលេខ១៣។

[១០] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែមទៀតរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៩ ឯកសារលេខ១៦ ("ចម្លើយតបទៅនឹងសេចក្តីណែនាំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ") កថាខណ្ឌទី ៥៨-៦២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

៨. កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែម និងដីកាសម្រេចកាលបរិច្ឆេទសវនាការ ("សេចក្តីណែនាំ") ដែលបានបញ្ជូនទៅសហព្រះរាជអាជ្ញាឲ្យឆ្លើយទៅនឹងសំណួរមួយចំនួនជាលាយលក្ខណ៍អក្សរ និងកំណត់កាលបរិច្ឆេទសវនាការ ដែលត្រូវធ្វើនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩ ហើយសវនាការនេះនឹងអាចលុបចោលទៅវិញ ប្រសិនបើអង្គបុរេជំនុំជម្រះទទួលបានព័ត៌មានគ្រប់គ្រាន់ តាមរយៈចម្លើយតបដែលដាក់ជូនដោយសហព្រះរាជអាជ្ញា[១១]។

៩. សហព្រះរាជអាជ្ញាទាំងពីរ បានឆ្លើយតបទៅតាមពេលវេលាកំណត់ ដែលមាននៅក្នុងសេចក្តីណែនាំកាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩[១២]។ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបទៅនឹងបញ្ហា ដែលបានលើកឡើងនីមួយៗដោយយោងទៅតាមសេចក្តីណែនាំ។[១៣] ក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាទាំងពីរបានបញ្ចេញយោបល់ថា សវនាការជាសាធារណៈគឺមិនចាំបាច់ ហើយក៏មិនត្រូវការដែរ និងបានស្នើសុំឲ្យអង្គបុរេជំនុំជម្រះសម្រេចលើការខ្វែងយោបល់គ្នា ដោយឈរលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ។

១០. អង្គបុរេជំនុំជម្រះសម្រេចថា អង្គបុរេជំនុំជម្រះទទួលបានព័ត៌មានគ្រប់គ្រាន់ហើយ តាមរយៈសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលដាក់ជូនដោយសហព្រះរាជអាជ្ញា និងសម្រេចថាសវនាការមិនមានភាពចាំបាច់ ដើម្បីទទួលបាននូវព័ត៌មានបន្ថែមទៀតស្តីពីបញ្ហាដែលបាន

[១១] សេចក្តីណែនាំ របស់អង្គបុរេជំនុំជម្រះ ឲ្យដាក់ឯកសារពិស្តារបន្ថែមនិងដីកាកំណត់កាលបរិច្ឆេទ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៩ ឯកសារលេខ១៥។

[១២] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីណែនាំ។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែមទៀតរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៩ និងសេចក្តីសង្ខេបបន្ថែមរបស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ ឯកសារលេខ១៧ ("ចម្លើយតបទៅនឹងសេចក្តីណែនាំរបស់សហព្រះរាជអាជ្ញាជាតិ")។

[១៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះឲ្យដាក់ឯកសារពិស្តារបន្ថែម ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ឯកសារលេខ១៨ ("ចម្លើយតបទៅនឹងសេចក្តីណែនាំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ")។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះឲ្យដាក់ឯកសារពិស្តារបន្ថែម ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ឯកសារលេខ១៩ ("ចម្លើយតបទៅនឹងសេចក្តីណែនាំរបស់សហព្រះរាជអាជ្ញាជាតិ")។



PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

លើកឡើងដោយភាគីនោះទេ ហើយជាលទ្ធផលបានលុបចោលនូវសវនាការ ដែលគ្រោងធ្វើនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩[១៨]។

## II. អំពីក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ

១១. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា មាត្រា៦(១) និង(៤)នៃ "កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ "កិច្ចព្រមព្រៀង" បានចែងដោយឡែកពីគ្នាថា៖

"១. មានព្រះរាជអាជ្ញាខ្មែរមួយរូប និងព្រះរាជអាជ្ញាអន្តរជាតិមួយរូប ដែលមានសមត្ថកិច្ចបង្ហាញខ្លួននៅក្នុងអង្គជំនុំជម្រះក្តីទាំងពីរថ្នាក់ ដោយបម្រើការជាសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាទទួលខុសត្រូវលើការងារចោទប្រកាន់"។

[...]

"៤. សហព្រះរាជអាជ្ញាត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការចោទប្រកាន់។ ក្នុងករណីដែលព្រះរាជអាជ្ញាមិនអាចឯកភាពគ្នាថា ត្រូវបន្តការចោទប្រកាន់ណាមួយ ការចោទប្រកាន់នោះត្រូវដំណើរការទៅមុខទៀត លើកលែងតែព្រះរាជអាជ្ញាទាំងពីរនេះ ឬព្រះរាជអាជ្ញាណាមួយក្នុងចំណោមព្រះរាជអាជ្ញាទាំងពីរ ធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃឲ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា៧"។[១៩]

១២. មាត្រា៧ នៃកិច្ចព្រមព្រៀងបានចែងបន្តទៀតថា៖

"<u>ការដោះស្រាយនូវការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ឬ សហព្រះរាជអាជ្ញា</u>

---

[១៨] សេចក្តីសម្រេចលើបញ្ហាកំណត់អំពីការខ្វែងយោបល់គ្នាដោយឈរលើមូលដ្ឋានអំណះអំណាងជាលាយលក្ខណ៍អក្សរតែឯង ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៩ ឯកសារលេខ២០។

[១៩] បទបញ្ញត្តិស្រដៀងគ្នាអាចរកឃើញបាននៅក្នុងមាត្រា ២០(ថ្មី) នៃច្បាប់ អ.វ.ត.ក។

១. ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញាបានធ្វើសំណើស្របតាមមាត្រា៥ វាក្យខណ្ឌ៤ ឬមាត្រា៦ វាក្យខណ្ឌ៤ តាមករណីដែលកើតឡើង សហចៅក្រមស៊ើបអង្កេត ឬសហ-ព្រះរាជអាជ្ញា ត្រូវធ្វើឯកសាររាយការណ៍ជាលាយលក្ខណ៍អក្សរពីអង្គហេតុ និង ហេតុផលបញ្ជាក់ពីគោលជំហរខ្វែងគំនិតគ្នារបស់ខ្លួន ដាក់ជូនប្រធានការិយាល័យរដ្ឋបាល។

២. ការខ្វែងគំនិតគ្នានេះនឹងត្រូវដោះស្រាយជាបន្ទាន់ដោយ "អង្គបុរេជំនុំជម្រះ" មួយដែលមានចៅក្រមប្រាំរូប ដែលបីរូបតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានមួយរូប ជាប្រធាន និងពីររូបទៀតតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមសំណើរបស់លោកអគ្គលេខាធិការ។ ការជ្រើសរើសចៅក្រមនេះ ត្រូវអនុវត្តតាមមាត្រា ៣ វាក្យខណ្ឌទី៣។

៣. ពេលដែលទទួលបានឯកសាររាយការណ៍ដូចបានចែងក្នុងវាក្យខណ្ឌទី១ ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះភ្លាម និងបែងចែកឯកសាររាយការណ៍នេះជូនដល់សមាជិកអង្គបុរេជំនុំជម្រះ។

៤. ការសម្រេចសេចក្ដីរបស់អង្គបុរេជំនុំជម្រះ ដែលមិនអាចប្ដឹងឧទ្ធរណ៍បាន ត្រូវមានសំឡេងឆ្នោតគាំទ្រដោយចៅក្រមយ៉ាងតិចបួនរូប។ ការសម្រេចសេចក្ដីនេះត្រូវជូនដល់ប្រធានរដ្ឋបាលដែលនឹងផ្សព្វផ្សាយ ហើយចែកជូនដល់សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា។ សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញានឹងត្រូវដំណើរការភ្លាមៗស្របទៅតាមការសម្រេចរបស់អង្គបុរេជំនុំជម្រះ។ ប្រសិនបើគ្មានមតិភាគច្រើន ដែលត្រូវការសម្រាប់ធ្វើការសម្រេចសេចក្ដីទេ ការស៊ើបអង្កេត ឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត។"

១៣. មាត្រា១៦ នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់អ.វ.ត.ក") បានយកតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀង និងបានចែងថា:

"រាល់ការសន្និដ្ឋានចោទប្រកាន់ជូនទៅអង្គជំនុំជម្រះវិសាមញ្ញ គឺជាការទទួលខុសត្រូវរបស់ព្រះរាជ-អាជ្ញាពីររនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេសដែលហៅថា "សហព្រះរាជអាជ្ញា" ដែលត្រូវធ្វើការរួមគ្នាដើម្បីរៀបចំឯកសារ និងធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ជនសង្ស័យសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ"។

១៤. មាត្រា២០ ថ្មី ច្បាប់ អ.វ.ត.ក ចែងបន្តទៀតថា៖

"សហព្រះរាជអាជ្ញា ត្រូវធ្វើការចោទប្រកាន់ ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន។ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហព្រះរាជអាជ្ញាអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

ក្នុងករណីដែលមានភាពខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម៖

ការចោទប្រកាន់ត្រូវបន្ត ដរាបណាសហព្រះរាជអាជ្ញា ឬក៏សហព្រះរាជអាជ្ញាម្នាក់ពុំបានស្នើក្នុងរយៈពេលសាមសិបថ្ងៃថា ភាពខ្វែងយោបល់គ្នាត្រូវបានដោះស្រាយ ដោយអនុលោមតាមបទប្បញ្ញត្តិដូចខាងក្រោម៖

សហព្រះរាជអាជ្ញាត្រូវដាក់ជូននូវកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីអង្គហេតុ និងហេតុផលទាំងឡាយចំពោះគោលជំហរខុសគ្នារបស់គេដល់ប្រធានការិយាល័យរដ្ឋបាល។ ភាពខ្វែងយោបល់គ្នាត្រូវតែដោះស្រាយភ្លាមដោយអង្គបុរេជំនុំជម្រះដែលមានចៅក្រមប្រាំរូប ចៅក្រមខ្មែរបីរូប ត្រូវបានជ្រើសតាំងដោយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានចៅក្រមមួយរូបជាប្រធាន ហើយនិង ចៅក្រមបរទេសពីររូប ត្រូវបានជ្រើសតាំងដោយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម បន្ទាប់ពីមានការជ្រើសរើសឲ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ។ ការជ្រើសរើសចៅក្រមខាងលើនេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា១០ ថ្មីនៃច្បាប់នេះ។

បន្ទាប់ពីទទួលបានកំណត់ហេតុដូចដែលមានចែងនៅក្នុងកថាខ័ណ្ឌទី៣ ប្រធានការិយាល័យរដ្ឋបាល ត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ ហើយត្រូវជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលពុំបើកផ្លូវឱ្យមានបណ្តឹងឧទ្ធរណ៍តម្រូវឱ្យ មានសំឡេងវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាល"។

១៥. វិធាន៧១ នៃវិធានផ្ទៃក្នុង ផ្តល់ឱ្យនូវយន្តការសម្រាប់ដោះស្រាយការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាទាំងពីរ៖

"១. ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាណាមួយ ឬទាំងពីរ អាចធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះ ដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទ ហើយត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយក្រឡាបញ្ជីនៃការិយាល័យសហព្រះរាជអាជ្ញា។

២. ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ សហព្រះរាជអាជ្ញាណាម្នាក់អាចនាំយកករណីខ្វែងយោបល់គ្នានេះទៅចំពោះមុខអង្គបុរេជំនុំជម្រះ តាមរយៈការបញ្ជូនឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នានេះទៅការិយាល័យរដ្ឋបាល។ ការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ និងបញ្ជូនឯកសារទាំងនេះទៅឱ្យចៅក្រមទាំងអស់ ដោយចម្លងជូនមួយច្បាប់ទៅឱ្យសហព្រះរាជអាជ្ញាម្ខាងទៀត។ ក្នុងករណីនេះ សហព្រះរាជអាជ្ញាម្ខាងទៀតអាចដាក់ជូនឯកសារឆ្លើយតបក្នុងរយៈពេល១០(ដប់)ថ្ងៃ។ ឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នា មិនត្រូវដាក់ចូលក្នុងសំណុំរឿងឡើយ។ ក្រឡាបញ្ជីរបស់សហព្រះរាជអាជ្ញា ត្រូវបញ្ជូនសំណុំរឿងថតចម្លងមួយច្បាប់ទៅឱ្យអង្គបុរេជំនុំជម្រះភ្លាម។

៣. ក្នុងអំឡុងពេលនៃការដោះស្រាយការខ្វែងយោបល់គ្នានេះ សហព្រះរាជអាជ្ញាត្រូវប្រឹងប្រែងស្វែងរកការឯកភាពគ្នា ។ កិច្ច ឬសេចក្តីសម្រេច ដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នានេះ ត្រូវតែយកទៅអនុវត្ត លើកលែងតែបញ្ហានៃការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងចំណុចដូចខាងក្រោម ៖

ក- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

ខ- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋថ្មី

គ- ដីកាសន្និដ្ឋានស្ថាពរ ឬ

ឃ- សេចក្តីសម្រេចពាក់ព័ន្ធទៅនឹងការប្តឹងឧទ្ធរណ៍

ក្នុងករណីទាំងនេះគ្មានសកម្មភាពណាមួយដែលពាក់ព័ន្ធទៅនឹងការខ្វែងគំនិតគ្នាត្រូវបានអនុវត្តទេ រហូតដល់មានការព្រមព្រៀងគ្នាណាមួយត្រូវបានសម្រេចឡើង ឬ រយៈពេល៣០ (សាមសិប) ថ្ងៃត្រូវបានកន្លងផុត ឬអង្គបុរេជំនុំជម្រះបានទទួលយករឿងខ្វែងយោបល់គ្នាមកជំនុំជម្រះ ហើយបានបញ្ចប់នីតិវិធីដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ។

៤. អង្គបុរេជំនុំជម្រះ ត្រូវដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ ដូចខាងក្រោម ៖

ក- សវនាការរបស់អង្គបុរេជំនុំជម្រះត្រូវរៀបចំធ្វើឡើង និងប្រកាសសាលក្រមជាសម្ងាត់។ ការចូលរួមពីចម្ងាយអាចធ្វើទៅបានតាមការចាំបាច់។

ខ- អង្គបុរេជំនុំជម្រះដោយអំណាចឆន្ទានុសិទ្ធិ អាចបង្គាប់ឱ្យសហព្រះរាជអាជ្ញាចូលមកបង្ហាញខ្លួនដោយផ្ទាល់ រួមទាំងការបង្ហាញវត្ថុតាង។

គ- សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឱ្យមានសម្លេងគាំទ្រពីចៅក្រម ៤(បួន) រូបយ៉ាងតិច។ សេចក្តីសម្រេចនេះបិទផ្លូវប្តឹងឧទ្ធរណ៍។ ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចរកបានសម្លេងគាំទ្រភាគច្រើនតាមការតម្រូវទេ ដោយអនុលោមតាមមាត្រា ២០ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រភាគច្រើនមានន័យថាកិច្ច ឬសេចក្តីសម្រេចដែលបានធ្វើដោយសហព្រះរាជអាជ្ញាណាម្នាក់ត្រូវមានសុពលភាព ឬមានន័យថាកិច្ច ឬសេចក្តីសម្រេច ដែលបម្រុងនឹងធ្វើដោយសហព្រះរាជអាជ្ញាម្នាក់ត្រូវតែយកមកអនុវត្ត។

ឃ- រាល់សេចក្តីសម្រេចទាំងអស់ដែលមានចែងក្នុងវិធាននេះ រួមទាំងគំនិតជំទាស់ផងត្រូវមានបញ្ជាក់មូលហេតុ និងចុះហត្ថលេខាដោយសាមីខ្លួន។ ក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះត្រូវបញ្ជូនសេចក្តីសម្រេចនេះទៅឱ្យប្រធានការិយាល័យរដ្ឋបាលដែលត្រូវជូនដំណឹងដល់សហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាត្រូវបន្តកិច្ចដំណើរការនីតិវិធីជាបន្ទាន់ ស្របតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ”។

១៦. អង្គបុរេជំនុំជម្រះសង្កេតឃើញថា បទបញ្ញត្តិច្បាប់ដែលបានលើកឡើងខាងលើ ឆ្លុះបញ្ចាំងថាចាប់តាំងពីពេលដែលកិច្ចព្រមព្រៀងត្រូវបានសម្រេច គេបានយល់ដឹងជាមុនថា ការខ្វែងយោ-

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

បល់គ្នាអាចកើតមានឡើងរវាងសហព្រះរាជអាជ្ញាទាំងពីរ ប៉ុន្តែបទបញ្ញត្តិទាំងនោះក៏បានចែងថា សហព្រះរាជអាជ្ញាទាំងពីរត្រូវសហការគ្នា ក្នុងការអនុវត្តន៍កិច្ច ឬសេចក្តីសម្រេចទាំងនោះ។ មាត្រា ៦(១) និង(៤) នៃកិច្ចព្រមព្រៀង ,មាត្រា ១៦ និង២០(ថ្មី) នៃច្បាប់ អ.វ. ត.ក និងវិធាន ៧១(៣) នៃវិធានផ្ទៃក្នុង បានបង្ហាញយ៉ាងច្បាស់លាស់ថា ព្រះរាជអាជ្ញាមួយអាចធ្វើសកម្មភាព ដោយគ្មានការព្រមព្រៀងពីព្រះរាជអាជ្ញាមួយទៀតបាន ប្រសិនបើពុំមានព្រះរាជអាជ្ញាណាមួយនាំយកនូវការខ្វែងយោបល់នេះមកដោះស្រាយ នៅចំពោះមុខអង្គបុរេជំនុំជម្រះ នៅក្នុងពេលវេលាដែលបានកំណត់ជាក់លាក់ទេនោះ។ អង្គបុរេជំនុំជម្រះក៏បានសង្កេតឃើញថែមទៀតថា មានតែពេលដែលបញ្ហាគួរឱ្យព្រួយបារម្ភដ៏សំខាន់ ដែលបានបង្ហាញអត្ថសញ្ញាណយ៉ាងជាក់លាក់នៅក្នុងវិធានផ្ទៃក្នុងមានការពាក់ព័ន្ធប៉ុណ្ណោះ ទើបការខ្វែងយោបល់គ្នានេះនឹងរារាំងព្រះរាជអាជ្ញាមួយ មិនឱ្យបន្តសកម្មភាពណាមួយ ដោយត្រូវផ្អាករង់ចាំរហូតមានសេចក្តីសម្រេចពីអង្គបុរេជំនុំជម្រះ។ ក្នុងចំណោមចំណុចពិសេសទាំងនោះ គឺមានចំណុចនៃការខ្វែងយោបល់គ្នា ទាក់ទងទៅនឹងការចេញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរថ្មីនេះ ។

១៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថែមទៀតថា សម្លេងគាំទ្រពីចៅក្រម ៤(បួន)រូប យ៉ាងតិចគឺជាលក្ខខណ្ឌកំណត់ឱ្យឈានដល់ការចេញសេចក្តីសម្រេច ដើម្បីរាំងស្ទះមិនឱ្យមានការអនុវត្តន៍សេចក្តីសម្រេច ដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា។ ប្រសិនបើមិនទទួលបាននូវមតិភាគច្រើនលើសលុបទេនោះ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រភាគច្រើន គឺថាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នឹងត្រូវបញ្ជូនទៅសហចៅក្រមស៊ើបអង្កេតដើម្បីបើកកិច្ចស៊ើបសួរ។

## III. ភាពអាចទទួលយកបាននៃការខ្វែងយោបល់គ្នា

១៨. នៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិ មិនបានចង្អុលបង្ហាញនៅក្នុងឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សររបស់គាត់ថា ការខ្វែងយោបល់គ្នាកើតមានឡើងនៅពេលណាទេនោះ នៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិបានលើកឡើងថា៖

"កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានប្រជុំពិភាក្សាគ្នាអំពីបញ្ហានៃការប្តឹងចោទជនសង្ស័យថ្មីបន្ថែមទៀត ដើម្បីបញ្ជូនទៅសហចៅក្រមស៊ើបអង្កេតឲ្យបើកការស៊ើបសួរ។ ជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងកិច្ចពិភាក្សានោះ គឺមានបំណងដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទី២ ចំនួនមួយ បញ្ចូលក្នុងសំណុំរឿងលេខ ០០២ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីចំនួនពីរ សម្រាប់សំណុំរឿងលេខ០០៣ និងលេខ០០៤។ ចំណែកឯសហព្រះរាជអាជ្ញាជាតិ មិនឯកភាពក្នុងការធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះឡើយ។ ទាំងនេះ គឺជាចំណុចនៃការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ"[១៦]។

១៩. នៅក្នុងអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ និងបានជូនដំណឹងមកអង្គបុរេជំនុំជម្រះ ដោយការិយាល័យរដ្ឋបាលកាលពីថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៨។ ការខ្វែងយោបល់គ្នាត្រូវបញ្ជូនមកការិយាល័យរដ្ឋបាលក្នុងរយៈពេលកំណត់៣០ថ្ងៃ ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង និងដូច្នេះ ហើយទើបត្រូវបានទទួលយក។

[១៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីអង្គហេតុនិងមូលហេតុខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញាអន្តរជាតិ យោងតាមវិធាន ៧១(២) ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ ឯកសារលេខ៧ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា [illegible]")។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

## IV. តួនាទី និងវិសាលភាពក្នុងការពិនិត្យមើលឡើងវិញរបស់អង្គបុរេជំនុំជម្រះ

២០. កិច្ចព្រមព្រៀង ច្បាប់អ.វ.ត.ក និងវិធានផ្ទៃក្នុង មិនបានចង្អុលបង្ហាញឱ្យបានច្បាស់លាស់ថា តើអង្គបុរេជំនុំជម្រះត្រូវដោះស្រាយករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញាតាមរបៀបណានោះទេ។ យោងតាមវិធាន៧១(៤)(ក) និង(ខ) នៃវិធានផ្ទៃក្នុង ផ្តល់ឱ្យត្រឹមតែយន្តការមួយ ដែលអង្គបុរេជំនុំជម្រះអាចកោះហៅសហព្រះរាជអាជ្ញាចូលមកបង្ហាញខ្លួនតាមរយៈសវនាការ ឬផ្តល់ជូននូវឯកសារភស្តុតាង។ មុខនាទីរបស់អង្គបុរេជំនុំជម្រះ ក្នុងបញ្ហានេះ គឺជាមុខនាទីពិសេសតែមួយគត់ ដែលមិនមានតុលាការណាផ្សេងទៀត មាននាទីដោះស្រាយការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញានោះឡើយ។

២១. ក្នុងការពាក់ព័ន្ធទៅនឹងតួនាទីដែលថា អង្គបុរេជំនុំជម្រះគួរតែបំពេញភារកិច្ចក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានជូនយោបល់នៅក្នុងអំណះអំណាងជាលាយ-លក្ខណ៍អក្សររបស់គាត់ថា៖

"១៦. បទដ្ឋាននៃការពិនិត្យឡើងវិញដែលត្រូវយកមកប្រើប្រាស់ដោយ អ.ប.ជ គឺថា តើគេមានមូលហេតុនាំឱ្យជឿបានទេថា បទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការនៃ អ.វ.ត.ក ពិតជាបានប្រព្រឹត្តឡើងមែននោះ។ វិធាន៥៣.១ នៃវិធានផ្ទៃក្នុងចែងថា "ប្រសិនបើសហព្រះរាជអាជ្ញាមានហេតុផលជឿថា ឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ បានកើតមានពិតមែន សហព្រះរាជអាជ្ញាត្រូវបើកការស៊ើបសួរ..."។ នេះគឺជាលក្ខខណ្ឌតម្រូវដ៏មានសារសំខាន់ចាំបាច់តែមួយគត់ សម្រាប់បើកការស៊ើបសួរណាមួយ ស្របតាមវិធាន៥៣ នៃវិធានផ្ទៃក្នុង។ ហេតុដូចនេះ វាគឺជាលក្ខខណ្ឌតែមួយគត់ ដែល អ.ប.ជ អាចពិនិត្យឡើងវិញ ស្របតាមវិធាន៧១ [...]។"

សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ជូនបន្ថែមទៀតទៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងសេចក្តីណែនាំ៖

"១៣. នៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដំណើរការនៃនីតិវិធីនេះគឺមាន



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

លក្ខណៈជាអាជ្ញាកណ្ដាល (មជ្ឈត្តកម្ម) នៅចន្លោះរវាងភាគីចំនួនពីរ ដោយតុលាការអាជ្ញាកណ្ដាលមួយដែលឯករាជ្យ។ ភាគីទាំងពីរ (ក្នុងករណីរឿងនេះគឺសហព្រះរាជអាជ្ញា) អនុញ្ញាតផ្ដល់យុត្តាធិការទៅឱ្យតុលាការអាជ្ញាកណ្ដាលនោះ (ដែលនៅទីនេះគឺអង្គបុរេជំនុំជម្រះ) ដោយការប្ដឹងទៅតុលាការនោះអំពីការខ្វែងយោបល់គ្នាខាងលើនេះ។ វិសាលភាពនៃដំណើរការនៃនីតិវិធីត្រូវបានកំរិតត្រឹមតែបញ្ហាដែលបានលើកឡើងនៅក្នុងសេចក្ដីថ្លែងការណ៍របស់អ្នកដែលស្នើសុំ (ដែលនៅទីនេះគឺសហព្រះរាជអាជ្ញាអន្តរជាតិ) និងសេចក្ដីថ្លែងការណ៍ឆ្លើយតបដោយអ្នកឆ្លើយតប (ដែលនៅទីនេះគឺសហព្រះរាជអាជ្ញាជាតិ) ។ តុលាការអាជ្ញាកណ្ដាលកំណត់សម្រេចលើបញ្ហាផ្សេងៗដែលបានលើកឡើងនៅក្នុងសេចក្ដីថ្លែងការណ៍ និងក្លាយទៅជាតុលាការដែលលែងមានសិទ្ធិអំណាចតទៅទៀត *(functus officio)* ក្រោយពេលបានបំពេញភារកិច្ចរបស់ខ្លួនក្នុងការកំណត់សម្រេចរួចរាល់ហើយ។ [...] ”

២២. នៅក្នុងចម្លើយតបរបស់ខ្លួន ទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជ-អាជ្ញាអន្តរជាតិនោះ សហព្រះរាជអាជ្ញាជាតិ “សូមស្នើដល់អង្គបុរេជំនុំជម្រះមិនគួរធ្វើការពិចារណាអំពីមូលហេតុនៃការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជ-អាជ្ញាអន្តរជាតិ ដោយផ្អែកតែលើវិធាន ៥៣ នៃវិធានផ្ទៃក្នុងតែមួយនោះទេ ក៏ប៉ុន្តែសូមស្នើដល់អង្គបុរេជំនុំជម្រះ លើកយកច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក និងកិច្ចព្រមព្រៀងមកធ្វើការពិចារណារួមគ្នាផងដែរ” [១៧]។ សហព្រះរាជអាជ្ញាជាតិបានលើកឡើងបន្ថែមទៀតថា៖

“៧៥. គោលជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺជំទាស់ទៅនឹងសិទ្ធិរបស់អង្គបុរេជំនុំជម្រះក្នុងការពិនិត្យការអនុវត្តន៍ឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា ក្នុងការដោះស្រាយវិវាទនាពេលបច្ចុប្បន្ននេះ។ សហព្រះរាជអាជ្ញាជាតិ មិនយល់ស្របតាមន័យតូចចង្អៀតនៃសមត្ថកិច្ចរបស់អង្គបុរេជំនុំជម្រះឡើយ ហើយសូមស្នើដល់អង្គបុរេជំនុំជម្រះ គួរតែពិនិត្យឱ្យបានពេញលេញនូវហេតុផលទាំងឡាយរបស់សហព្រះរាជអាជ្ញាជាតិ។

៧៦. ភាពខ្វែងយោបល់គ្នាដែលនាំយកទៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយអនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង គឺទាក់ទងជាសំខាន់នឹងឆន្ទានុសិទ្ធិចោទប្រកាន់។ គោលជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិថា ឆន្ទានុសិទ្ធិបែបនេះគួរតែមិនត្រូវបានកំណត់ ឬកំណត់ដាច់ខាតត្រឹមណានោះទេ។

[១៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី ៧៣។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ប៉ុន្តែអាចបកស្រាយបានថា អង្គបុរេជំនុំជម្រះអាចចូលដោះស្រាយបានត្រឹមតែមានសហព្រះរាជអាជ្ញាណាម្នាក់បានសម្រេច ឬមានចេតនាសម្រេចផ្ទុយពីច្បាប់ដែលបានចងកាតព្វកិច្ចប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ទំហំសមត្ថកិច្ចដោះស្រាយវិវាទតូចចង្អៀតនេះ មិនបានស្តែងឲ្យឃើញថាមិនសមស្របនឹងតួនាទីរបស់អង្គបុរេជំនុំជម្រះ លើការដោះស្រាយវិវាទនៃការខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញានោះទេ។"

២៣. យោងតាមមាត្រា៦ នៃកិច្ចព្រមព្រៀង តួនាទីរបស់អង្គបុរេជំនុំជម្រះក្នុងបរិបទនេះ "គឺដើម្បីដោះស្រាយនូវការខ្វែងយោបល់គ្នា" រវាងសហព្រះរាជអាជ្ញា "ដែលមិនអាចឯកភាពគ្នាថាតើត្រូវបន្តដំណើរការចោទប្រកាន់ណាមួយឬអត់។" ក្នុងគោលដៅនេះ វិធាន៧១(១) បានចែងថា សហព្រះរាជអាជ្ញាត្រូវ "ធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទ ហើយត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែកដែលរក្សាទុកដោយក្រឡាបញ្ជីនៃការិយាល័យសហព្រះរាជ-អាជ្ញា។" វិធាន៧១(២) បានបញ្ជាក់ថែមទៀតថា សហព្រះរាជអាជ្ញាដែលសម្រេចចិត្តនាំយកករណីខ្វែងយោបល់គ្នានេះទៅអង្គបុរេជំនុំជម្រះ "ត្រូវដាក់ជូននូវឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នា"។

២៤. ស្របជាមួយនឹងបទបញ្ញត្តិទាំងអស់នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បទដ្ឋាននៃការពិនិត្យរបស់ខ្លួន ត្រូវកម្រិតត្រឹមចំណុចវិវាទដែលលើកឡើងដោយសហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ ចំពោះបញ្ហានេះ អង្គបុរេជំនុំជម្រះត្រូវតែពិចារណាត្រឹមតែហេតុការណ៍ និងមូលហេតុដែលបានប្តឹងមកនៅចំពោះមុខខ្លួនដោយសហព្រះរាជអាជ្ញាប៉ុណ្ណោះ។ យោងតាមវិធាន ៧១ (២) អង្គហេតុ និងមូលហេតុទាំងនេះ ត្រូវបានកំណត់នៅក្នុងសារណាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងនៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ។ បន្ថែមពីលើព័ត៌មានដែលសហព្រះរាជអាជ្ញាបានផ្តល់ជូននៅក្នុងដីកាសន្និដ្ឋានទាំងនេះ សហព្រះរាជ-អាជ្ញាទាំងពីរ ត្រូវបានអង្គបុរេជំនុំជម្រះស្នើឲ្យធ្វើការបំភ្លឺបន្ថែមអំពីការខ្វែងយោបល់គ្នារបស់ខ្លួនតាមរយៈសេចក្តីណែនាំឲ្យផ្តល់ព័ត៌មានពិស្តារបន្ថែមចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨។ ស្ថិតក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះត្រូវពិចារណាទៅលើអង្គហេតុ និងមូលហេតុ



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE C.E.T.C. C.C.C.

ទាំងឡាយដែលបានលើកឡើងនៅក្នុងចម្លើយតប និងសារណាតបទៅនឹងសេចក្តីណែនាំដែលបានដាក់ដោយសហព្រះរាជអាជ្ញាទាំងពីរ។

២៥. ការខ្វែងយោបល់គ្នានេះ គឺដោយសារតែសហព្រះរាជអាជ្ញាអន្តរជាតិមានបំណងបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី ទៅសហចៅក្រមស៊ើបអង្កេតសម្រាប់បើកការស៊ើបសួរស្របតាមវិធាន៥៣(១) ដើម្បីបង្កើតបានជាសំណុំរឿង០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស និង ០០៤/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស។ ប៉ុន្តែសហព្រះរាជអាជ្ញា-ជាតិជំទាស់។

២៦. យោងតាមមាត្រា៦(១) និង(៤) និងមាត្រា៧(៤) នៃកិច្ចព្រមព្រៀង, មា ត្រា ១៦ និងមាត្រា២០ (ថ្មី) នៃច្បាប់ អ.វ.ត.ក និងវិធាន៧១(៤)(គ) នៃវិធានផ្ទៃក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី នឹងត្រូវបញ្ជូនទៅចៅក្រមស៊ើបអង្កេត លុះត្រាតែយ៉ាងហោចណាស់ចៅក្រមនៃអង្គបុរេជំនុំជម្រះចំនួនបួនរូប បានពេញចិត្តថា អំណះអំណាងដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាជាតិ ត្រូវច្រានចោលនូវការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ខ្លួនត្រូវតែពិនិត្យមើលលើអំណះអំណាងដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាជាតិ និងសម្រេចថា តើទង្វើករណ៍ទាំងនេះអាចទប់ស្កាត់មិនឲ្យបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី ទៅសហចៅក្រមស៊ើបអង្កេតដើម្បីបើកការស៊ើបសួរបានដែរឬទេ។ អង្គបុរេជំនុំជម្រះ ត្រូវតែសម្រេចលើអំណះអំណាងទាំងនេះដោយឯករាជ្យ។ ទោះបីជាអង្គបុរេជំនុំជម្រះត្រូវបានជួយ ជាជំនួយដោយអំណះ-អំណាង ដែលបានផ្តល់ជូនដោយសហព្រះរាជអាជ្ញាអន្តរជាតិក៏ដោយ ក៏សហព្រះរាជអាជ្ញាអន្តរជាតិ មិនទទួលបន្ទុកក្នុងការធ្វើឲ្យអង្គបុរេជំនុំជម្រះជឿទុកចិត្តថា ដីកាបញ្ជូនរឿងឲ្យស៊ើបសួរថ្មី នឹងត្រូវបញ្ជូនទៅចៅក្រមស៊ើបអង្កេតដើម្បីបើកការស៊ើបសួរ ឬថាអំណះអំណាង ដែលលើកឡើងដោយសហព្រះរាជអាជ្ញាជាតិ ត្រូវតែបដិសេធចោលនោះដែរ។

២៧. មាត្រា៦(១)និង(៤) នៃកិច្ចព្រមព្រៀង និងមាត្រា១៦ និង២០(៣) (ថ្មី) នៃច្បាប់ អ.វ.ត.ក បង្ហាញឲ្យឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី ក្រោយពីការផ្ដល់ឲ្យរយៈពេលសាមសិបថ្ងៃតាមការជូនដំណឹងដល់សហព្រះរាជអាជ្ញាជាតិ ប្រសិនបើការខ្វែងយោបល់គ្នាមិនត្រូវបានបញ្ជូនមកនៅចំពោះមុខអង្គបុរេជំនុំជម្រះទេនោះ។ ហេតុនេះ បញ្ហានេះមិនត្រូវបានគិតទុកជាមុនថា ការខ្វែងយោបល់គ្នាត្រូវបានបញ្ជូនដោយសហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានពន្យល់អំពីការយល់ឃើញរបស់ខ្លួន អំពីមូលហេតុដែលសហព្រះរាជអាជ្ញាជាតិជំទាស់ទៅនឹងការសម្រេចចិត្តរបស់គាត់ ក្នុងការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីនោះទេ។ បើអនុវត្តតាមនីតិវិធីត្រឹមត្រូវនោះ គឺសហព្រះរាជអាជ្ញាជាតិទេ ដែលជាអ្នកជំទាស់ទៅនឹងការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីទាំងនោះ ត្រូវដាក់សារណាជាលាយលក្ខណ៍អក្សររបស់គាត់មុន ប៉ុន្តែទោះជាវិធីបែបណាក៏ដោយនៃការនាំយកការខ្វែងយោបល់គ្នាមកដោះស្រាយនៅចំពោះមុខអង្គបុរេជំនុំជម្រះ នឹងមិនប៉ះពាល់ដល់វិធី ដែលអង្គបុរេជំនុំជម្រះត្រូវពិចារណាលើបញ្ហានោះទេ។

## V. យោបល់របស់សហព្រះរាជអាជ្ញាជាតិ និងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

### ក. យោបល់របស់សហព្រះរាជអាជ្ញាជាតិ

២៨. ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាជាតិ ត្រូវបានលើកឡើងក្នុងចម្លើយតបរបស់គាត់ទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងត្រូវបានពន្យល់បន្ថែមទៀតនៅក្នុងសារណាតប និងចម្លើយតបរបស់គាត់ទៅនឹងសេចក្ដីណែនាំ។ នៅក្នុងសេចក្ដីសង្ខេបនេះ អង្គបុរេជំនុំជម្រះបានរៀបចំទឡ្ហីករណ៍ទាំងនោះ ស្របជាមួយនឹងអ្វីដែលគេយល់ថា ជាបញ្ហាចំបងដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាជាតិ។ សេចក្ដីសង្ខេបខ្លីមួយ ស្ដីពីចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានធ្វើតាមក្រោយ។

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

## ភាពចាំបាច់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី ("បញ្ហាទីមួយ")

២៩. សហព្រះរាជអាជ្ញាជាតិបានលើកឡើងថា មិនចាំបាច់មានដីកាសន្និដ្ឋានថ្មីនោះទេ។ អង្គហេតុ និងឧក្រិដ្ឋកម្មដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានថ្មី គឺមានរួចហើយនៅក្នុងសមត្ថកិច្ច ស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ពីព្រោះអង្គហេតុ និងឧក្រិដ្ឋកម្មទាំងនោះមាន នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីមួយ កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ហើយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីមួយ អាចធ្វើឡើងតែនៅពេលណា "ដែលមាន អង្គហេតុថ្មីកើតឡើង ហើយដែលអង្គហេតុថ្មីនោះ មិនមាននៅក្នុងការស៊ើបអង្កេតដែលកំពុង ដំណើរការប៉ុណ្ណោះ"[១៨]។ ជាពិសេស សហព្រះរាជអាជ្ញាជាតិជំទាស់ទៅនឹងដីកាសន្និដ្ឋាន បញ្ជូនរឿងឲ្យស៊ើបសួរថ្មីទាំងអស់ដោយមូលហេតុថា ៖

> "៥០. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ នៅក្នុងនោះ បានពណ៌នាអំពីឧក្រិដ្ឋកម្មដូចខាងក្រោម៖
>
> - ការជម្លៀសដោយបង្ខំ
> - ការបង្ខំឲ្យធ្វើពលកម្ម
> - ការធ្វើឲ្យទៅជាទាសករ
> - លក្ខខណ្ឌរស់នៅបែបអមនុស្សធម៌
> - ការចាប់ខ្លួន និងការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់
> - ការបំពានលើរូបរាងកាយ និងស្មារតី
> - ការធ្វើទារុណកម្ម និង
> - ការធ្វើមនុស្សឃាត។
>
> ដីកាសន្និដ្ឋានបញ្ជូនឲ្យស៊ើបសួរនេះបានបន្តលើកឡើងថា បទឧក្រិដ្ឋទាំងនេះបានកើតឡើងទូទាំង ប្រទេសកម្ពុជា ហើយមានជនរងគ្រោះស្លាប់ដោយអំពើទាំងអស់នេះ សរុបជាង ១.៧លាន នាក់

---

[១៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី៩២ និង៣៩។ សូមមើលផងដែរ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី៥០, ៨៤ដល់៨៥។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី១៣ ដល់១៥, ១៨។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ក្នុងអម្លុងកម្ពុជាប្រជាធិបតេយ្យកាន់អំណាចពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

៥១. តាមន័យដូចបានរៀបរាប់នៅកថាខណ្ឌ៥០ ខាងលើ អាចបញ្ជាក់បានថា អង្គហេតុរៀបរាប់រឿងរ៉ាវជារួមនៃឧក្រិដ្ឋកម្មក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យកាន់អំណាច គឺសហព្រះរាជ-អាជ្ញាបានធ្វើការប្តឹងចោទប្រកាន់ទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកការស៊ើបសួររួចហើយ។ ក្នុងអង្គហេតុនោះបានបញ្ជាក់ថា មានជនរងគ្រោះជាង ១.៧លាននាក់ បានបាត់បង់ជីវិត។ ដូច្នេះការស្លាប់ទាំងនេះនៅគ្រប់មន្ទីរសន្តិសុខនានាទូទាំងផ្ទៃប្រទេសកម្ពុជា និងនៅគ្រប់ការដ្ឋានបង្ខំឲ្យធ្វើការហួសកម្លាំង ស្លាប់ដោយអត់អាហារ ស្លាប់ដោយជម្ងឺអត់ថ្នាំព្យាបាលនិងស្លាប់ដោយបញ្ហាផ្សេងៗទៀត។ [redacted]។

៥២. យោងតាមកថាខណ្ឌ ៥១ ខាងលើនេះ អាចបញ្ជាក់បានថា អង្គហេតុទាំងមូលនៃឧក្រិដ្ឋកម្មក្នុងអម្លុងពេលកម្ពុជាប្រជាធិបតេយ្យកាន់អំណាច ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ គឺកំពុងតែស្ថិតនៅក្នុងសមត្ថកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត។ ដូច្នេះសហព្រះរាជអាជ្ញាមិនគួរបើកការស៊ើបសួរបន្ថែម ឬបើកការស៊ើបសួរថ្មីលើអង្គហេតុដដែលនេះទៀតទេ។

៥៣. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម គឺធ្វើនៅពេលណាដែលអង្គហេតុចាស់ដែលមាននៅក្នុងការស៊ើបសួររួចហើយនោះមានលេចអង្គហេតុថ្មី ហើយអង្គហេតុថ្មីនោះ មិនទាន់បានពណ៌នានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមុននៅឡើយ។ ដូច្នេះសហព្រះរាជអាជ្ញាជាតិសន្និដ្ឋានថា ការធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិនេះមិនមែនជាការចាំបាច់ទេ[១៩]។

---

[១៩] អង្គបុរេជំនុំជម្រះមិនបានទទួលការខ្វែងយោបល់គ្នាថែមទៀតពាក់ព័ន្ធនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទៀតទេ ប៉ុន្តែកថាខណ្ឌនេះត្រូវបានដកស្រង់ដើម្បីពន្យល់ពីមូលហេតុទាំងមូលរបស់សហព្រះរាជអាជ្ញាជាតិពាក់ព័ន្ធនឹងការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទៀត។

៥៤. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី គឺត្រូវធ្វើឡើងសម្រាប់អង្គហេតុថ្មី ដែលអង្គហេតុនោះមិនទាន់មាននៅក្នុងកិច្ចស៊ើបសួរនៅឡើយទេ ។ ដូច្នេះសហព្រះរាជអាជ្ញាជាតិសូមស្នើថា ការធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីរបស់សហព្រះរាជអាជ្ញាអន្តរជាតិនេះ មិនមែនជាការចាំបាច់ទេ"[២០]។

៣០. សហចៅក្រមព្រះរាជអាជ្ញាជាតិបានអះអាងថែមទៀតថា សហព្រះរាជអាជ្ញាមិនត្រូវបើកការស៊ើបសួរថ្មីទៀតទេ ដោយសារតែសហចៅក្រមស៊ើបអង្កេតអាចបើកកិច្ចស៊ើបសួររបស់ខ្លួនទៅលើជនសង្ស័យថ្មីបាន ទោះបីជាជនសង្ស័យថ្មីទាំងនេះមិនមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ[២១]។

## ការអនុវត្តន៍អំណាចឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់ ("បញ្ហាទីពីរ")

៣១. លើសពីនេះ សហព្រះរាជអាជ្ញាជាតិមិនឯកភាពក្នុងការធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឡើយ ដោយហេតុថា ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀងតម្រូវឱ្យមានការជ្រើសរើសក្នុងការចោទប្រកាន់ ពីព្រោះ អ.វ.ត.ក មានអាណត្តិដើម្បីកាត់សេចក្តីតែមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ ទី៦ ខែមករា ឆ្នាំ១៩៧៩ តែប៉ុណ្ណោះ[២២]។ ព្រះរាជអាជ្ញាជាតិយល់ឃើញថា អ.វ.ត.ក មិនមានបំណង ឬមិនអាចបំពេញទៅតាមគោលការណ៍នៃយុត្តិធម៌ល្អឥតខ្ចោះ និងនាំយកមកកាត់សេចក្តីនូវជនទាំងឡាយណា ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដោយ

---

[២០] ការផ្ទុះបញ្ចាំងដែលបានបន្ថែម។ សូមមើលផងដែរ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី៨២ ដល់៨៥។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី១៤, ១៧ ដល់១៨។

[២១] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី៨៤, ៨៥ និង ៨៦(ឃ)។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី៨ និង១៨។

[២២] សូមមើលមាត្រា ១ និង ២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង មាត្រា ៦(៣) នៃកិច្ចព្រមព្រៀង។

សារតែ អ.វ.ត.ក មានកម្រិតយុត្តាធិការចំពោះបុគ្គល និងពេលវេលា[២៣]។ សហព្រះរាជអាជ្ញាជាតិបានលើកឡើងថា ការជ្រើសរើសជនសង្ស័យនីមួយៗ មកធ្វើការចោទប្រកាន់ ត្រូវតែឆ្លុះបញ្ចាំងអំពីគោលបំណងនិងស្មារតីនៃច្បាប់ អ.វ.ត.ក កិច្ចព្រមព្រៀង និងបុព្វកថានៃវិធានផ្ទៃក្នុង៖ ដើម្បីថែរក្សាឯកភាពជាតិ ការបង្រួបបង្រួមជាតិ ស្ថេរភាព សុវត្ថិភាព និងសន្តិភាពក្នុងប្រទេសកម្ពុជា[២៤]។ គោលដៅទាំងនេះ ត្រូវតែផ្តល់អាទិភាពឲ្យមុនគេបំផុត លើសពីអ្វីដែលមានចែងក្នុងវិធាន៥៣ នៃវិធានផ្ទៃក្នុង ហើយដូច្នេះ ការចោទប្រកាន់មិនគួរត្រូវផ្តួចផ្តើមឡើងគ្រប់ករណីទាំងអស់ដែលមាន "ហេតុផលនាំឲ្យជឿថា" មានអំពើឧក្រិដ្ឋកម្មបានកើតមានឡើងនោះឡើយ[២៥]។ ក្នុងការអនុវត្តន៍ "អំណាច ឆន្ទានុសិទ្ធក្នុងការចោទប្រកាន់" របស់ខ្លួន សហព្រះរាជអាជ្ញាជាតិ បានជំទាស់ជាមួយនឹងការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី ដោយមូលហេតុចំនួនបីយ៉ាងដូចខាងក្រោម៖

៣២. ចំណុចទី១ សហព្រះរាជអាជ្ញាជាតិយល់ឃើញថា ជនសង្ស័យដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានថ្មី មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុតនោះទេ ពីព្រោះពួកគាត់មានតួនាទីទាបក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូច្នេះហើយពួកគាត់មិនត្រូវស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក នោះទេ ("ទឡ្ហីករណ៍យុត្តាធិការ")[២៦]។

៣៣. ចំណុចទី២ សហព្រះរាជអាជ្ញាជាតិបានលើកឡើងថា ការឲ្យតម្លៃខ្ពស់ចំពោះសន្តិភាព ស្ថេរ-ភាព និងការបង្រួបបង្រួមជាតិក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន គឺជាតឹកតាងប្រឆាំងទៅនឹងការផ្តួចផ្តើមគំនិតថ្មីក្នុងការចោទប្រកាន់ ជាពិសេសដោយយល់ឃើញថាតួនាទីរបស់សហព្រះ

---

[២៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី៨ ដល់១១។

[២៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី១២។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី៥៥។

[២៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី១២។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី៦៥។

[២៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី៥០, ៦២ ដល់៦៣។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី៦។ សូមមើលផងដែរ សំណុំសំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអន្តរជាតិ កថា...

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

រាជអាជ្ញាគឺធ្វើបណ្តឹងអាជ្ញាដើម្បីការពារ “ផលប្រយោជន៍សាធារណៈរបស់សង្គមកម្ពុជា” (“ទឡ្ហីករណ៍ផលប្រយោជន៍សាធារណៈ”)[២៧]។

៣៤. ជាពិសេស សហព្រះរាជអាជ្ញាជាតិអះអាងថា កិច្ចដំណើរការរបស់ អ.វ.ត.ក មិនទាន់នាំឱ្យមានអស្ថិរភាព ឬប្រតិកម្មជាហិង្សាដោយអតីតទាហានខ្មែរក្រហមនោះទេ “ពីព្រោះសាធារណជនយល់ឃើញថា សិទ្ធិអំណាចរបស់អ.វ.ត.ក ត្រូវបានកម្រិតត្រឹមតែការកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត” តែប៉ុណ្ណោះ[២៨]។ ប្រសិនបើការចោទប្រកាន់ចំពោះមន្ត្រីជាន់ទាបត្រូវបានផ្តួចផ្តើមគំនិតធ្វើដូចទៅនឹងអ្វី ដែលបានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីនោះ ការយល់ឃើញនេះនឹងផ្លាស់ប្តូរហើយ “អតីតសមាជិក និងអ្នកដែលមានភក្តីភាពចំពោះមេដឹកនាំខ្មែរក្រហមអាចប្រព្រឹត្តសកម្មភាពហិង្សា”[២៩]។ អតីតមន្ត្រីខ្មែរក្រហមជាន់ទាបនឹងមានការរអាក់រអួលក្នុងការធ្វើជាសាក្សី ពីព្រោះភ័យខ្លាចថាពួកគាត់អាចក្លាយជាមុខសញ្ញានៃការស៊ើបអង្កេតរបស់ អ.វ.ត.ក[៣០]។ ប្រសិនបើការស៊ើបអង្កេតអាចគ្របដណ្តប់ទៅលើជនសង្ស័យ ដែលជាមន្ត្រីជាន់ទាបដូចនេះ “នោះនឹងមានជនសង្ស័យក្នុងកម្រិតនេះជាច្រើនដែលត្រូវធ្វើការចោទប្រកាន់” ហើយនឹងអាច “មានផលប៉ះពាល់ជាអវិជ្ជមានដល់ស្ថេរភាពនៅក្នុងប្រទេសកម្ពុជា”[៣១] និងបង្កើតបានជា “ស្ថានភាពបះបោរដ៏គួរឱ្យភ័យខ្លាចមួយនៅក្នុងសង្គមកម្ពុជា” ជាពិសេសក្នុងចំណោមអ្នកដែលមានឋានន្តរសក្តិប្រហាក់ប្រហែលគ្នា[៣២]។

៣៥. យោងទៅតាមសហព្រះរាជអាជ្ញាជាតិ ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀងទទួលស្គាល់ថា “ការសម្រេចបាននូវការបង្រួបបង្រួមជាតិ គឺជាកត្តាមួយដ៏សំខាន់បំផុតសម្រាប់សង្គមកម្ពុជា”

---

[២៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី១៧។

[២៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី១៥។

[២៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី១៥។

[៣០] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី៦១។

[៣១] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី១២។

[៣២] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី៦៤។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

ពីព្រោះច្បាប់ និងកិច្ចព្រមព្រៀងទាំងនេះ បានផ្តល់ឱ្យមានការជ្រើសរើសក្នុងការចោទប្រកាន់ប្រឆាំងចំពោះមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត។[៣៣] ឯកភាពជាតិក្នុងប្រទេសកម្ពុជាទើបតែទទួលបានក្នុងឆ្នាំ១៩៩៦ ប៉ុណ្ណោះ តាមរយៈការធ្វើសមាហរណកម្មមេដឹកនាំ និងកងទ័ពខ្មែរក្រហមទៅក្នុងសង្គមកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា[៣៤]។ ការផ្តួចផ្តើមគំនិតចោទប្រកាន់ថ្មី មិនមែនជាសមាសភាពជាអាយុជីវិតដើម្បីធានាដល់សន្តិភាព និងស្ថេរភាពនៅក្នុងប្រទេសកម្ពុជានោះទេ[៣៥] ប៉ុន្តែផ្ទុយទៅវិញ អាចធ្វើឱ្យរាំងស្ទះដល់ឯកភាពជាតិដែលមានលក្ខណៈផុយស្រួយ និងការបន្តបង្រួបបង្រួមជាតិ។

៣៦. សហព្រះរាជអាជ្ញាជាតិបានបន្ថែមអំណះអំណាងទៀតថា ការចោទប្រកាន់បន្ថែម អាចគំរាមកំហែងដល់សុវត្ថិភាពជាតិកម្ពុជា ដោយយោងទៅលើស្ថានភាពបញ្ហាព្រំដែលនាពេលបច្ចុប្បន្ននៅតំបន់ព្រះវិហារ "ដែលនៅទីនោះអតីតកងទ័ពខ្មែរក្រហមស្ថិតនៅខ្សែត្រៀមជួរមុខដើម្បីការពារបូរណភាពដែនដី និងអធិបតេយ្យភាពកម្ពុជា"[៣៦] [redacted][៣៧]។

៣៧. ចំណុចទី៣ សហព្រះរាជអាជ្ញាជាតិបាលលើកឡើងថា ការផ្តួចផ្តើមគំនិតថ្មីក្នុងការចោទប្រកាន់ គឺទាមទារឱ្យមាននូវតម្រូវការសំខាន់ៗបន្ថែមទៀតដូចជា ធនធានមនុស្ស ហិរញ្ញវត្ថុ និងពេលវេលា "ហើយដែលទីបំផុតមិនអាចគេចផុតនោះគឺនាំឱ្យមានបញ្ហាមិនពិតប្រាកដកើតមានឡើង។" ការលះបង់ធនធានដ៏មានកំណត់ដែលមាននៅក្នុង អ.វ.ត.ក នាពេលបច្ចុប្បន្នសម្រាប់ការចោទប្រកាន់ថ្មី នឹងនាំឱ្យសវនាការដែលកំពុងដំណើរការនាពេលបច្ចុប្បន្ន "ស្ថិត

---

[៣៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី១៤។

[៣៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី១៣។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី៦៧ ដល់៦៨។

[៣៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី៧៨។

[៣៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី១៥។

[៣៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី៦៣។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី[illegible]។

នៅក្នុងភាពមហន្តរាយ"។[៣៨] ធនធានមនុស្ស និងហិរញ្ញវត្ថុដ៏មានកំណត់នៅ អ.វ.ត.ក ក៏ដូចជាតម្រូវការដើម្បីបញ្ចប់សវនាការនៅក្នុងរយៈពេលមួយសមស្រប គឺជាបញ្ហាដែលត្រូវពិចារណា ដើម្បីគាំទ្រដល់ការជ្រើសរើសក្នុងការចោទប្រកាន់ និងប្រឆាំងជំទាស់ទៅនឹងដីកាសន្និដ្ឋានថ្មី ("ទឡ្ហីករណ៍ធនធាន")[៣៩]។

**អនីត្យានុកូលភាពនៃកិច្ចស៊ើបសួរបឋម ("បញ្ហាទីបី")**

៣៨. នៅក្នុងសារណាតប និងចម្លើយតបទៅនឹងសេចក្តីណែនាំ សហព្រះរាជអាជ្ញាជាតិបានផ្តល់អំណះអំណាងថា សហព្រះរាជអាជ្ញាអន្តរជាតិបានដឹកនាំកិច្ចស៊ើបសួរបឋមរហូតដល់ចេញជាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី ដោយខ្លួនគាត់មិនបានដឹង ឬមិនបានចូលរួមជួយអ្វីនោះទេ[៤០]។ គាត់បានលើកឡើងទៀតថា កិច្ចស៊ើបសួរបឋមដែលធ្វើឡើងដោយឯកតោភាគីរហូតដល់ចេញជាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី គឺបានរំលោភទៅលើច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ដូច្នេះដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី ត្រូវតែបដិសេធចោល[៤១]។

## ខ. យោបល់របស់សហព្រះរាជអាជ្ញាអន្តរជាតិ

៣៩. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងនូវការជំទាស់បឋមពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃបញ្ហាទីមួយ និងទីបី ក៏ដូចជាទឡ្ហីករណ៍យុត្តាធិការពាក់ព័ន្ធនឹងបញ្ហាទីពីរផងដែរ។ គាត់សន្និដ្ឋានថា បញ្ហាទាំងនេះត្រូវបានលើកឡើង "យឺតពេលណាស់ទៅហើយនៅក្នុងកិច្ចដំណើរការនីតិវិធី និងច្បាស់ណាស់ថា គឺជាការគិតឃើញនាពេលក្រោយមក" នៅពេលដែលបញ្ហាទាំងនោះត្រូវបានសហព្រះរាជអាជ្ញាលើកឡើងជាលើកដំបូងនៅក្នុងសារណាតបទៅនឹង

[៣៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី១៦។

[៣៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី៧០ ដល់៧១។

[៤០] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី១៩។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី២២ ដល់២៥។

[៤១] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី២០។

សេចក្តីណែនាំរបស់គាត់ បន្ទាប់ពីការខ្វែងយោបល់គ្នាត្រូវបានបង្ហាញឱ្យឃើញច្បាស់នៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៨[៤២]។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមស្នើដល់អង្គបុរេជំនុំជម្រះមិនអើពើ ឬច្រានចោលបញ្ហានានា ដែលបានលើកឡើងយឺតពេលទាំងអស់នេះ។

៤០. សហព្រះរាជអាជ្ញាអន្តរជាតិបានតវ៉ាថែមទៀតថា បញ្ហាទីបី គឺភាពមិនអាចទទួលបាន ដោយសារថា និយ័តភាពនៃកិច្ចស៊ើបសួរបឋមមិនទាក់ទង ទៅនឹងការកំណត់សម្រេចអំពីកិច្ចដំណើរការនីតិវិធីទាំងនេះនោះទេ នៅពេលដែលបញ្ហាចោទតែមួយគត់ដើម្បីធ្វើការកំណត់ គឺថាតើដីកាសន្និដ្ឋានថ្មីគួរតែបញ្ជូនទៅសហចៅក្រមស៊ើបអង្កេតដែរឬទេ។ ហេតុនេះ អង្គបុរេជំនុំជម្រះ ពុំមានយុត្តាធិការ ដើម្បីពិចារណាអំពីការជំទាស់នេះទេ[៤៣]។

៤១. ចំពោះខ្លឹមសារនៃបញ្ហាដែលសហព្រះរាជអាជ្ញាជាតិបានលើកឡើង សហព្រះរាជអាជ្ញាអន្តរ-ជាតិបានឆ្លើយតបថា "លក្ខណៈវិនិច្ឆ័យតែមួយគត់ដែលត្រូវធ្វើការកំណត់ថា តើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវដំណើរការឬអត់ ស្របតាមវិធាន ៥៣ នៃវិធានផ្ទៃក្នុង គឺជាបទដ្ឋាននៃ "ហេតុផលជឿបាន"។ ដូចដែលសហព្រះរាជអាជ្ញាជាតិបានឯកភាពថា មានហេតុផលជឿថា បទឧក្រិដ្ឋនោះបានប្រព្រឹត្តឡើងមែន កិច្ចស៊ើបសួរត្រូវតែដំណើរការ។ សហព្រះរាជអាជ្ញាអន្តរជាតិតវ៉ាថា ទឡ្ហីករណ៍ដែលលើកឡើងដោយសហព្រះរាជអាជ្ញាជាតិ មិនមានភាពពាក់ព័ន្ធទេ ចំពោះវិធាន ៥៣ នៃវិធានផ្ទៃក្នុង។ ទឡ្ហីករណ៍ទាំងនោះ ក៏មិនស្របជាមួយនឹងគោលបំណងដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញនោះដែរ ដែលនាំយកមេដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តិឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យចន្លោះពីឆ្នាំ១៩៧៥ និង ១៩៧៩[៤៤]។

---

[៤២] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី៥។

[៤៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី១១ ដល់១៥។

[៤៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី១១ ដល់១២។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. * C.E.T.C.

៤២. ពាក់ព័ន្ធនឹងបញ្ហាទីមួយ ទាក់ទិននឹងភាពចាំបាច់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងយ៉ាងច្បាស់លាស់ថែមទៀតថា:

"១៧. [...] ការទាញជាសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាជាតិ ហាក់បីដូចជាថា ក្នុងចំណោមដីកាសន្និដ្ឋានថ្មីៗទាំងនោះមួយណាក៏ជាន់គ្នាដែរ (ដែលកំពុងតែត្រូវស្រូបចូលទៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) ឬសហព្រះរាជអាជ្ញាមិនមានសិទ្ធិអំណាចក្នុងការស្នើសុំឱ្យមានការស៊ើបសួរជាថ្មីទាំងនោះទេ ដោយសារសហព្រះរាជអាជ្ញាបានប្តឹងអំពីអង្គហេតុទាំងនោះ ដល់សហចៅក្រមស៊ើបអង្កេតរួចហើយ។

១៨. សហព្រះរាជអាជ្ញា បានពោលអះអាងជាដាច់ខាតនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី១ របស់ខ្លួនហើយថា សហព្រះរាជអាជ្ញាបាននិងកំពុងប្តឹងទៅសហចៅក្រមស៊ើបអង្កេត តែអំពីឈុតនៃអង្គហេតុនៃអំពើឧក្រិដ្ឋកម្មតែចំនួន ២៥ឈុត ដែលត្រូវបានបង្ហាញអត្តសញ្ញាណនៅក្នុងដីកាសន្និដ្ឋាននោះតែប៉ុណ្ណោះ។ ការយល់ឃើញរបស់សហព្រះរាជអាជ្ញានេះ ត្រូវបានគូសបញ្ជាក់ឱ្យដឹងតាមរយៈការប្តឹងរបស់សហព្រះរាជអាជ្ញាទៅសហចៅក្រមស៊ើបអង្កេតជាបន្តបន្ទាប់ តាមកាលកំណត់អំពីអង្គហេតុ និង/ឬអំពីឧក្រិដ្ឋកម្មថ្មីៗ ឧទាហរណ៍ដូចជា អង្គហេតុដែលពាក់ព័ន្ធទៅនឹងមណ្ឌលសន្តិសុខថ្មីណាមួយ ឧក្រិដ្ឋកម្មពីបទរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាដើម។ល។ តាមពិត ដោយសារការយល់ឃើញនេះ សហព្រះរាជអាជ្ញាបានផ្តល់អំណាចដល់សហចៅក្រមស៊ើបអង្កេត ឱ្យធ្វើការស៊ើបសួរអំពីអង្គហេតុជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាទាំងមូល គឺគ្រាន់តែបង្ហាញឱ្យឃើញការពិតអំពីលក្ខណៈវិនិច្ឆ័យខាងយុត្តាធិការសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់តែប៉ុណ្ណោះ"[៤៥]។

៤៣. ពាក់ព័ន្ធនឹងបញ្ហាទីបី ទាក់ទិននឹងអនីត្យានុកូលភាពនៃកិច្ចស៊ើបសួរបឋមដែលបានលើកឡើង សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា កិច្ចស៊ើបសួរបឋមគឺប្រកបដោយសុពលភាពផង និងអាចអនុញ្ញាតឱ្យធ្វើបានផងដែរ ដែលជាគោលការណ៍បានធ្វើរួចហើយដោយឈរលើមូលដ្ឋាននៃការវិភាគឯកសារនានាដែលមានស្រាប់នៅនឹងកន្លែង ដែលប្រមូលបានមុនតាំងពីមុនថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ និងដោយមានការព្រមព្រៀងរបស់សហព្រះរាជអាជ្ញាជាតិផង

[៤៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី១៧-១៨។

ដែរ។ ក្នុងករណីណាក៏ដោយ ដោយសន្មតថា កិច្ចស៊ើបសួរបឋមនោះត្រូវបាន "ធ្វើឡើងដោយឯកតោភាគី" នោះ សហព្រះរាជអាជ្ញាអន្តរជាតិបានតវ៉ាថា"មានការអនុញ្ញាតឲ្យធ្វើបានដែរ ផ្អែកតាមវិធានផ្ទៃក្នុង ឲ្យតែការខ្វែងយោបល់គ្នានោះត្រូវបានធ្វើឲ្យបានឃើញច្បាស់លាស់ និងជាក់លាក់ នៅក្នុងដំណាក់កាលនៃការចុះហត្ថលេខាលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម"[៤៦]។

## VI. ការបញ្ចេញយោបល់

៤៤. ក្រោយពេលពិគ្រោះយោបល់ដ៏តឹងតែងរួចមក អង្គបុរេជំនុំជម្រះមិនអាចស្វែងរកសម្លេងភាគច្រើន ដើម្បីសម្រេចចិត្តលើបញ្ហាខ្វែងយោបល់គ្នានេះទេ។ ប៉ុន្តែអង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័នទៅលើមធ្យោបាយបញ្ជាក់ពីវិធីសាស្ត្ររបស់អង្គជំនុំជម្រះនៅក្នុង "សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ" ទាំងនេះ។ ដោយសារតែវិធាន ៧១(៤)(ឃ) នៃវិធានផ្ទៃក្នុងចែងថា សេចក្តីសម្រេច អំពីការខ្វែងយោបល់គ្នាត្រូវមានបញ្ជាក់មូលហេតុ និងដើម្បីធានានូវតម្លាភាព អង្គបុរេជំនុំជម្រះយល់ឃើញថា វាមានភាពចាំបាច់ នៅក្នុងការបញ្ជាក់អំពីការបញ្ចេញយោបល់ផ្សេងៗគ្នាពីសមាជិករបស់អង្គជំនុំជម្រះ ដែលយោបល់ទាំងនោះត្រូវបានភ្ជាប់ជាមួយនឹងសេចក្តីពិចារណាទាំងអស់នេះ។

## VII. សេចក្តីសន្និដ្ឋាន

៤៥. នៅពេលដែលអង្គបុរេជំនុំជម្រះ មិនឈានដល់ការធ្វើសេចក្តីសម្រេចលើការខ្វែងយោបល់គ្នា ដែលត្រូវបាននាំយកមកដោះស្រាយនៅចំពោះមុខខ្លួនទេនោះ វិធាន ៧៤(១) នៃវិធានផ្ទៃក្នុងចែងថា កិច្ចរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវតែយកទៅអនុវត្ត។ នៅក្នុងករណីនេះ មានន័យថា សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីទៅ

---

[៤៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី១៦។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

សហចៅក្រមស៊ើបអង្កេតដើម្បីបើកកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៥៣(១) នៃវិធានផ្ទៃក្នុង។

## VIII. សេចក្តីពិចារណាពាក់ព័ន្ធនឹងការរក្សាការសម្ងាត់

៤៦. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា អនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង "ឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរ អំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នា មិនត្រូវដាក់ចូលក្នុងសំណុំរឿងឡើយ"។ វិធាន ៥៤ នៃវិធានផ្ទៃក្នុង ចែងថា "ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាសន្និដ្ឋានស្ថាពរ និងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ បន្ថែម ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា គឺជាឯកសារសម្ងាត់"។ វិធាន ៥៦(១) ចែងបន្ថែមទៀតថា "ដើម្បីការពារសិទ្ធិនិងផលប្រយោជន៍របស់ភាគី ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ។ បុគ្គលទាំងអស់ដែលចូលរួមក្នុងការស៊ើបសួរ ត្រូវរក្សាឲ្យបាននូវការសម្ងាត់។ យោងតាមបទបញ្ញត្តិទាំងនេះ ឯកសារទាំងអស់ដែលពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នា ត្រូវបានអង្គបុរេជំនុំជម្រះចាត់ចំណាត់ថ្នាក់ថាជា "ឯកសារសម្ងាត់បំផុត"។

៤៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថែមទៀតថា ផ្ទុយទៅនឹងគោលគំនិតនៃកាតព្វកិច្ចក្នុងការរក្សាការសម្ងាត់នេះ ការិយាល័យសហព្រះរាជអាជ្ញាបានចេញ "សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា" ជាសាធារណៈ កាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៨។ សហព្រះរាជអាជ្ញាបានជូនដំណឹងដល់សាធារណៈជនថា ការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាត្រូវបានដាក់រួចហើយ និងបានពណ៌នាថែមទៀតអំពីខ្លឹមសារនៃការខ្វែងយោបល់គ្នារបស់ខ្លួន។ ការិយាល័យសហព្រះរាជអាជ្ញាបានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈលើកទីពីរ កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩ ដែលរៀបរាប់ពិស្តារ អំពីមូលហេតុខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញាជាតិ និងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ តាមរយៈការធ្វើដូច្នេះ សហព្រះរាជអាជ្ញាបានទាញការយកចិត្តទុកដាក់ពីផ្នែកផ្សព្វផ្សាយព័ត៌មាន និងពីសាធារណៈជនលើហេតុការណ៍ដែលជនជាប់សង្ស័យថ្មីអាចត្រូវបានចោទប្រកាន់ ដោយបង្កើតឲ្យមានការពាក់ព័ន្ធខ្លាំងទៅនឹង



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ផលប្រយោជន៍ និងបានផ្ដល់ធ្វើការជូនដំណឹងដោយប្រយោលដល់ជនជាប់សង្ស័យដែលអាចមានថា អាចនឹងមានការចោទប្រកាន់ថែមទៀត។

៤៨. សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ចេញសេចក្ដីថ្លែងការណ៍ព័ត៌មានលើកទីបី កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ ពាក់ព័ន្ធនឹង "សេចក្ដីណែនាំឱ្យដាក់ឯកសារពិស្ដារបន្ថែម និងដីកាសម្រេចកាលបរិច្ឆេទសវនាការ" ដែលញ៉ាំងឱ្យអង្គបុរេជំនុំជម្រះ ចេញសេចក្ដីរំលឹកអំពីកាតព្វកិច្ចរក្សាការសម្ងាត់ដល់សហព្រះរាជអាជ្ញាទាំងពីរ។

៤៩. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា មាត្រា ៧(១) នៃកិច្ចព្រមព្រៀង និងមាត្រា ២០(ថ្មី)(៧) នៃច្បាប់ អ.វ.ត.ក ចែងថា សេចក្ដីសម្រេចលើការខ្វែងយោបល់គ្នារវាងសហព្រះរាជ-អាជ្ញា "ត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយសេចក្ដីសម្រេចនេះ ហើយជូនដំណឹងដល់សហព្រះរាជអាជ្ញា"។ ផ្ទុយទៅវិញ វិធាន ៧១(៤)(ក) ចែងថា សាលក្រម "ត្រូវប្រកាស*ជាសម្ងាត់*"។ អនុកឋាខណ្ឌ (ឃ) នៃវិធានដដែល ចែងថែមទៀតថា "ក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះត្រូវបញ្ជូនសេចក្ដីសម្រេចនេះ ទៅឱ្យប្រធានការិយាល័យរដ្ឋបាល ដែលត្រូវជូនដំណឹងដល់សហព្រះរាជអាជ្ញា" ដោយមិនមានការលើកឡើងថា សេចក្ដីសម្រេចត្រូវធ្វើការផ្សព្វផ្សាយនោះទេ។

៥០. លើសពីនេះទៀត វិធាន ៧៨ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការបោះពុម្ពផ្សាយសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះចែងថា "រាល់សេចក្ដីសម្រេចដែលមានសម្លេងគាំទ្រគ្រប់គ្រាន់ និងរាល់សេចក្ដីសម្រេចដែលមិនមានសម្លេងគាំទ្រគ្រប់គ្រាន់ រួមទាំងមតិជំទាស់ផងត្រូវបោះពុម្ពផ្សាយទាំងស្រុង លើកលែងតែអង្គបុរេជំនុំជម្រះសម្រេចថា ការបោះពុម្ពផ្សាយនោះ អាចប៉ះ-ពាល់ដល់ផលប្រយោជន៍នៃការអង្កេតបឋម ឬការស៊ើបសួរ"។

៥១. ពាក់ព័ន្ធនឹងការរក្សាការសម្ងាត់ និងការបោះពុម្ពផ្សាយសេចក្ដីសម្រេចលើការខ្វែងយោបល់គ្នា អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅពេលធ្វើការប្រៀបធៀបជាមួយនឹងវិធានផ្ទៃក្នុង



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

មាត្រានានានៃកិច្ចព្រមព្រៀង និងមាត្រានានានៃច្បាប់ អ.វ.ត.ក ហាក់ដូចជាមិនស៊ីសង្វាក់គ្នា ពាក់ព័ន្ធនឹងបញ្ហាថាតើ សេចក្តីសម្រេចលើការខ្វែងយោបល់គ្នា ត្រូវយកទៅបោះពុម្ពផ្សាយ ឬទេនោះ។ កិច្ចព្រមព្រៀង ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុងទាំងអស់នោះបានចែងថា ប្រធានរដ្ឋបាល ត្រូវជូនដំណឹងដល់សហព្រះរាជអាជ្ញា អំពីសេចក្តីសម្រេចលើការខ្វែងយោបល់គ្នា។ បញ្ហានេះគួរតែចាត់ការភ្លាម ពីព្រោះបទបញ្ញត្តិដែលបានលើកឡើងខាងលើចែងថា សហ-ព្រះរាជអាជ្ញា ត្រូវដំណើរការភ្លាម អនុលោមតាមសេចក្តីសម្រេចនោះ។

៥២. យោងតាមវិធាន ៧៨ វិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះអាចកំណត់សម្រេចថា សេចក្តីសម្រេចមិនត្រូវបោះពុម្ពផ្សាយទាំងស្រុងនោះទេ ប្រសិនបើបោះពុម្ពផ្សាយនោះ នឹងសម្រុបសម្រួលនូវផលប្រយោជន៍នៃការស៊ើបអង្កេតបឋម ឬការស៊ើបសួរ។ ការខ្វែងយោបល់គ្នានេះ មានការពាក់ព័ន្ធនឹងការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរថ្មី។ ដោយបានផ្តល់នូវសេចក្តីថ្លែងការណ៍ដែលចេញដោយសហព្រះរាជ-អាជ្ញារួចហើយពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នារបស់ខ្លួននោះ ការបោះពុម្ពផ្សាយសំណៅកោសលុបស្តីពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ នឹងមិនមានផលប៉ះពាល់ផ្ទុយទៅលើការរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរ ដែលអាចធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតនោះទេ។ ហេតុនេះ អង្គបុរេជំនុំជម្រះ ស្នើឱ្យការិយាល័យរដ្ឋបាលនៃតុលាការនេះ បោះពុម្ពផ្សាយសំណៅកោសលុបស្តីពីសេចក្តីពិចារណាទាំងអស់នេះ ដែលបានភ្ជាប់មកជាមួយនៅក្នុងឧបសម្ព័ន្ធទី១។

៥៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ការបោះពុម្ពផ្សាយសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ គឺជាអំណាចឆន្ទានុសិទ្ធិរបស់ប្រធានរដ្ឋបាល។ ដីកាសន្និដ្ឋានថ្មី អាចត្រូវបានសហ-ព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯងធ្វើការបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត មុនពេលមានការបោះពុម្ពផ្សាយសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ។ ចំពោះគោលបំណងនៃការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯងនេះ សេច



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

០០១/១៨-១១-២០០៨-អវតក/អបជ

ក្ដីដកស្រង់មួយ ត្រូវបានភ្ជាប់ជាមួយនឹងសេចក្ដីពិចារណាទាំងអស់នេះ នៅក្នុងឧបសម្ព័ន្ធទីពីរ។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះ៖**

១) **ប្រកាស** ថា ការខ្វែងយោបល់អាចទទួលយកបាន។

២) **ប្រកាស** ថា មិនទទួលបាននូវសម្លេងគាំទ្រពីចៅក្រមប្អូនរូបយ៉ាងតិច ដើម្បីធ្វើសេចក្ដីសម្រេចលើការខ្វែងយោបល់គ្នានោះទេ។ ~~~~

**ភ្នំពេញ, ថ្ងៃទី១៨ខែ សីហា ឆ្នាំ ២០០៩**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

Rowan DOWNING **ន័យ ធុល** Katinka LAHUIS **ហួត វុទ្ធី**

០០១/១៨-១១-២០០៨-អ.វ.ត.ក/អ.ប.ជ

# យោបល់របស់ ចៅក្រម ប្រាក់ គឹមសាន, ចៅក្រម ន័យ ធុល និងចៅក្រម ហួត វុទ្ធី

## ក. អនីត្យានុកូលភាពនៃកិច្ចស៊ើបអង្កេតបឋម

១. សហព្រះរាជអាជ្ញាជាតិ តាមចម្លើយរបស់ខ្លួន ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ បានអះអាងថា តាមវិធានផ្ទៃក្នុងរាល់ការដឹកនាំការស៊ើបអង្កេតបឋម និងការចោទប្រកាន់ទាំងអស់សុទ្ធតែប្រើពាក្យ "សហព្រះរាជអាជ្ញា"។ បើព្រះរាជអាជ្ញាណាមួយបំពេញកិច្ចតែឯង ដោយគ្មានការផ្ទេរសិទ្ធិនោះ វាផ្ទុយទៅនឹងបញ្ញត្តិនៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលបានលើកឡើងថា វៀរ លែងតែសកម្មភាពទាំងឡាយ ដែលត្រូវធ្វើរួមគ្នាក្រោមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង វិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញាអាចផ្ទេរអំណាចទៅឱ្យព្រះរាជអាជ្ញាណាមួយ ក្នុងចំណោមសហព្រះរាជអាជ្ញាទាំងពីររូប តាមរយៈសេចក្តីសម្រេចរួមគ្នាជាលាយលក្ខណ៍អក្សរឱ្យបំពេញកិច្ចតែម្នាក់ឯងបាន។ ដូច្នេះឃើញថា ការបំពេញកិច្ចដែលធ្វើឡើងកន្លងមកទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ នោះគឺ សហព្រះរាជអាជ្ញាអន្តរជាតិ និងមន្ត្រីរបស់ខ្លួនធ្វើដោយឯកឯង មិនបានស្នើសុំ ឬ ពិភាក្សាពីសហព្រះរាជអាជ្ញាជាតិទេ។[១]

២. យោងតាមច្បាប់ អ.វ.ត.ក ការចោទប្រកាន់មានតម្លៃអាចទទួលយកបានតាមផ្លូវច្បាប់នោះលុះត្រាតែសហព្រះរាជអាជ្ញាទាំងពីរ ពោលគឺសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិមានការឯកភាពគ្នា ដោយយោងលើពាក្យបណ្តឹង ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួន។ កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក បានបញ្ជាក់ច្បាស់ថា នៅ អ.វ.ត.ក ត្រូវមានព្រះរាជអាជ្ញាពីររូបដែលហៅថា "សហព្រះរាជអាជ្ញា" ហើយត្រូវធ្វើការសហការគ្នាក្នុងការបំពេញការងារ។ ដូច្នេះឃើញថា ភស្តុតាងនានា ដែលទទួលបានពីការស៊ើបអង្កេតបឋមរបស់សហព្រះរាជ

[១] កថាខណ្ឌទី១៩ នៃឯកសារទី ១៧ ។



PRE-TRIAL CHAMBER E.C.C.C * C.E.T.C CHAMBRE PRELIMINAIRE

អាជ្ញាអន្តរជាតិទាក់ទងទៅនឹងជនសង្ស័យថ្មីទាំងនោះ សហព្រះរាជអាជ្ញាជាតិពុំដែលបានចូលរួម ឬ ផ្តល់សិទ្ធិអំណាចដល់មន្ត្រីរបស់ខ្លួន ក្នុងការចូលរួមស៊ើបអង្កេតនោះទេ។[២]

៣. សហព្រះរាជអាជ្ញាជាតិ និងមន្ត្រីរបស់ខ្លួនមិនដែលបានចូលរួម និង/ឬ គាំទ្រដល់ការស៊ើប-អង្កេតបឋមក្នុងការកំណត់មុខសញ្ញាជនសង្ស័យ ដើម្បីយកមកធ្វើការប្តឹងចោទប្រកាន់ ដូចដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ និងទី៣ ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិនោះទេ។ រហូតដល់ការស៊ើបអង្កេតបឋម ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ និងមន្ត្រីរបស់ខ្លួនបានចប់សព្វគ្រប់ ទើបសហព្រះរាជអាជ្ញាជាតិបានទទួលព័ត៌មានក្រៅផ្លូវការថា ខាងផ្នែកអន្តរជាតិបានធ្វើការអង្កេតបឋមទាក់ទងនឹងកិច្ចការមួយចំនួន ហើយការអង្កេតបឋមនេះក៏បានចប់សព្វគ្រប់រួចរាល់ហើយដែរ។ ពេលទទួលព័ត៌-មានដូចនេះ សហព្រះរាជអាជ្ញាជាតិបានទៅសួរនាំសហព្រះរាជអាជ្ញាអន្តរជាតិ ប៉ុន្តែពេលនោះសហព្រះរាជអាជ្ញាអន្តរជាតិអវត្តមាន ទើបសហព្រះរាជអាជ្ញាជាតិទៅជួបជាមួយសហ-ព្រះរាជអាជ្ញារងអន្តរជាតិគឺ លោក វីលៀម ស្មីត។ ពេលសួរនាំករណីអង្កេតបឋមនេះ លោកវីលៀមស្មីត បានប្រាប់ថា ពិតជាមានការស៊ើបអង្កេតបឋមដូចដែលសហព្រះរាជអាជ្ញាជាតិទទួលបានព័ត៌មាននោះមែនហើយលោក វីលៀម ស្មីត ក៏បានពោលពាក្យថា "សុំទោស" ចំពោះ ការធ្វើអង្កេតបឋមដោយឯកឯងនេះ ហើយសន្យាថា បើពេលក្រោយមានធ្វើអ្វីទៀតខ្លួននឹងជូនដំណឹងដល់សហព្រះរាជជាតិ។[៣]

៤. សហព្រះរាជអាជ្ញាអន្តរជាតិ បានធ្វើការសម្រេចចិត្តក្នុងការផ្តួចផ្តើមស៊ើបអង្កេតនេះដោយឯកឯង ដូច្នេះព្រះរាជអាជ្ញាជាតិមិនបានដឹងអំពីបញ្ហានេះទេ។[៤]

---

[២] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ, កថាខណ្ឌទី២០ ។

[៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ, កថាខណ្ឌទី២២ ។

[៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ, កថាខណ្ឌទី២៨ ។

៥. ព្រះរាជអាជ្ញាអន្តរជាតិ តាមចម្លើយរបស់ខ្លួន ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ បានអះអាងថា៖ កិច្ចស៊ើបសួរបឋមទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរលើកទីមួយ លើកទីពីរ និងលើកទីបី ជាគោលការណ៍ត្រូវបានឈរលើមូលដ្ឋាននៃការវិភាគឯកសារធ្វើឡើងនៅក្នុងតុលាការ ដែលប្រមូលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដែលបានទទួលមុនថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧, មានន័យថា មុនការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីមួយ។ ភាគច្រើនបំផុតនៃការអនុញ្ញាតសម្រាប់កិច្ចស៊ើបសួរបឋមនៅពេលណាត្រូវបានផ្តល់ដោយព្រះរាជអាជ្ញាណាម្នាក់ ឬសហព្រះរាជអាជ្ញាក៏ដោយ គឺត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ដែលអនុញ្ញាតដោយច្បាប់។[៥]

៦. ការិយាល័យសហព្រះរាជអាជ្ញា បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦។ តាមព័ត៌មានដែលរកបានចំពោះការិយាល័យនាពេលនោះ អ្នកស៊ើបអង្កេតរបស់ខ្លួនបានកំណត់អត្តសញ្ញាណជនសង្ស័យសក្តានុពល [redacted] នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ដែលជនសង្ស័យទាំងនេះ បានជាប់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការនេះ និងជនដែលស្ថិតក្នុងយុត្តាធិការបុគ្គលយ៉ាងសំខាន់របស់តុលាការនេះដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលអាចរកបានជាសាធារណៈ។ ប៉ុន្តែនៅថ្ងៃនោះ ជនសង្ស័យសក្តានុពលម្នាក់បានស្លាប់។ អាស្រ័យហេតុនេះ បញ្ជីឈ្មោះជនសង្ស័យសក្តានុពលទាំងអស់ត្រូវបានកាត់បន្ថយមកត្រឹម [redacted] ហើយការិយាល័យបានបើកកិច្ចស៊ើបសួរបឋមលើជនសង្ស័យទាំងអស់ [redacted] នោះ ទៅតាមឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា។[៦]

៧. មកដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៦ ការិយាល័យបានធ្វើសេចក្តីព្រាងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរសម្រាប់ជនសង្ស័យ [redacted]។ សេចក្តីព្រាងនៃដីកាសន្និដ្ឋានទាំងនេះ ត្រូវបានចែកជូន និងពិនិត្យឡើងវិញ ដោយសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាបានកំណត់ថា

---

[៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសេចក្តីណែនាំ, កថាខណ្ឌទី ៥០ ។

[៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីណែនាំ, កថាខណ្ឌទី៥១

កិច្ចស៊ើបសួរបឋមបន្ថែមនឹងតម្រូវឱ្យមានសម្រាប់ជនសង្ស័យ [redacted] នេះ។ បន្ទាប់មក សហព្រះរាជអាជ្ញាបានធ្វើការសម្រេចចិត្ត ដើម្បីផ្តល់អាទិភាពសម្រាប់ជនសង្ស័យដោយបានផ្អែកលើលក្ខណៈវិនិច្ឆ័យឯករាជ្យចំនួនពីរ៖ (១) ថាតើការិយាល័យមានភស្តុតាងគ្រប់គ្រាន់នៅក្នុងដៃហើយឬនៅ ដើម្បីបំពេញទៅលើលក្ខណៈវិនិច្ឆ័យនៃ "ហេតុផលជឿបាន" សម្រាប់ជន-សង្ស័យជាក់លាក់ណាម្នាក់ ស្ថិតក្នុងក្របខណ្ឌពេលវេលាខ្លីប្រហាក់ប្រហែលគ្នា និង (២) ឋានៈរបស់ជនសង្ស័យនៅក្នុងឋានានុក្រមនៃបក្សកុម្មុនីស្តកម្ពុជា។ ការវាយតម្លៃនេះ ជាលទ្ធផល បង្កើតបាននូវបញ្ជីមួយមានជនសង្ស័យ [redacted] ដែលជាប្រធានបទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងបញ្ជីមួយទៀតមានជនសង្ស័យ [redacted] ទាក់ទងនឹងជនសង្ស័យដែលត្រូវបន្តនៅក្នុងកិច្ចស៊ើបសួរបឋមតាមពេលវេលា និងធនធានដែលអនុញ្ញាត។[៧]

៨. មកដល់ដើមខែកក្កដា ឆ្នាំ២០០៧ ការិយាល័យបានបង្កើតសេចក្តីព្រាងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមួយដែលមានលក្ខណៈជឿនលឿន ដោយចង្អុលឈ្មោះជនសង្ស័យប្រាំមួយនាក់៖ នួន ជា, អៀង សារី, អៀង ធីរិទ្ធ, ខៀវ សំផន, ឌុច និង [redacted]។ ប៉ុន្តែក្នុងថ្ងៃស្នើដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីមួយនោះ ដូចបានជម្រាបជូនខាងលើសហព្រះរាជ-អាជ្ញាជាតិបានកំណត់ថា តាមទស្សនៈរបស់គាត់ ភស្តុតាងដែលបានបង្កើតឡើងសម្រាប់ជនសង្ស័យ [redacted] មិនបំពេញបាននូវលក្ខណៈវិនិច្ឆ័យនៃ "ហេតុផលឱ្យជឿបាន" ទេ។[៨]

៩. ក្រោយថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ការិយាល័យបានបន្តកិច្ចស៊ើបសួរបឋមលើជនសង្ស័យ [redacted] ទៀត។ ទោះជាយ៉ាងនេះក្តីដើមឆ្នាំ២០០៨ ការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") បានដឹងថា ជនសង្ស័យម្នាក់ក្នុងចំណោមជនសង្ស័យ [redacted] បានស្លាប់ហើយនៅពេលថ្មីៗនេះ ដោយបុព្វហេតុចៃដន្យ ដោយបន្សល់ទុកជនសង្ស័យ [redacted] ដល់ ក.ស.ព។ ក្នុងចន្លោះពេលនៃកិច្ចស៊ើបសួរបឋមបន្ថែមក្នុងឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានកំណត់ថា

[៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសេចក្តីណែនាំ, កថាខណ្ឌទី៥២ ។

[៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសេចក្តីណែនាំ, កថាខណ្ឌទី៥៣ ។

បទឧក្រិដ្ឋទាំងឡាយណា ដែលអាចត្រូវបានប្រព្រឹត្តឡើងដោយជនសង្ស័យ [redacted] ក្នុងចំណោមជនសង្ស័យបន្ថែម ទោះបីជាមិនមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ស្ថិតក្នុងយុត្តាធិការរបស់តុលាការ ឬ ភស្តុតាងភ្ជាប់ជនសង្ស័យទាំងនេះទៅក្នុងបទឧក្រិដ្ឋទាំងនោះ មិនអាចបង្កើតបានទៅតាមក្របខណ្ឌពេលវេលាសមស្របដោយសារធនធានសម្រាប់កិច្ចស៊ើបសួរក៏ដោយ។ កិច្ចស៊ើប-សួរបឋមនៅតែបានបន្តធ្វើទៅលើជនសង្ស័យ [redacted] ដែលនៅរស់។[៩]

១០. នៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរបឋម ដែលបានធ្វើឡើងចាប់ពីខែកក្កដា ឆ្នាំ ២០០៧ ដល់ខែវិច្ឆិកា ឆ្នាំ២០០៨ ទោះបីជាដឹងក៏ដោយ សហព្រះរាជអាជ្ញាជាតិបានបង្ហាញពីការមិនចង់ឲ្យមានកិច្ចស៊ើបសួរ ហើយស្របគ្នានេះដែរ ក៏ហាក់ដូចជាមិនលើកទឹកចិត្តដល់បុគ្គលិករបស់គាត់ឲ្យចូលរួមឲ្យបានសកម្មនៅក្នុងការងារនេះដែរ។ នៅខែតុលា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានត្រៀមរៀបចំនូវសេចក្តីព្រាងនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដោយចង្អុលឈ្មោះ [redacted]។ ច្បាប់ចម្លងជឿនលឿននៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះជាភាសាខ្មែរត្រូវបានផ្តល់ជូនទៅឲ្យសហព្រះរាជអាជ្ញាជាតិ និងទើបគាត់បាននិយាយអំពីអសមត្ថភាពរបស់គាត់ ក្នុងការបញ្ជូនដីកាសន្និដ្ឋានទាំងនោះទៅសហចៅក្រមស៊ើបអង្កេត ដែលនេះជាការស្តែងចេញឲ្យឃើញច្បាស់អំពីការខ្វែងយោបល់គ្នានេះ។[១០]

១១. លើសពីនេះទៀត នៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ ទៅនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះឲ្យដាក់ឯកសារបន្ថែម សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា៖

> "និយ័តភាពនៃកិច្ចស៊ើបសួរបឋម ដូចបានលើកឡើងនៅកថាខណ្ឌ ១.គ ខាងលើ មិនជាប់ពាក់ព័ន្ធទៅនឹងការកំណត់លើការខ្វែងយោបល់នេះទេ។ សហព្រះរាជអាជ្ញាអន្តរជាតិសូមប្រកាន់ជំហរថា បញ្ហាតែមួយគត់នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងអស់នេះ គឺអំពីថាតើដីកា

---

[៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសេចក្តីណែនាំ, កថាខណ្ឌទី៥៤ ។

[១០] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសេចក្តីណែនាំ, កថាខណ្ឌទី៥៥ ។

សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីទាំងពីរ និងដីកាសន្និដ្ឋានបញ្ជូន រឿងឱ្យស៊ើបសួរបន្ថែមមួយ គួរតែត្រូវបានបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត សម្រាប់កិច្ចស៊ើបសួរដែរឬទេ។ បញ្ហាអំពីភាពទៀងទាត់នៃកិច្ចស៊ើបសួរបឋម ប្រសិនបើមានសុពលភាពទាំងអស់នោះ វាត្រូវធ្លាក់ទៅលើតែយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ ដែលជាអ្នកអាចអនុញ្ញាតឱ្យភាគីដែលស្នើសុំនូវដំណោះស្រាយសមស្រប ចំពោះការទុកជាមោឃៈក្រោមវិធាន៧៦។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះ មិនមានយុត្តាធិការដើម្បីធ្វើការពិចារណាទៅលើអញ្ញត្រកម្មនេះទេ នៅក្នុងដំណាក់កាលនេះ និងនៅក្នុងកិច្ចដំណើរការទាំងនេះ។ នៅក្នុងព្រឹត្តិការណ៍ណាក៏ដោយកិច្ចស៊ើបសួរបឋមដែលនាំឱ្យមានការស៊ើបសួរថ្មីៗ គឺត្រូវបានធ្វើឡើងដោយត្រឹមត្រូវ។"

១២. ក្នុងខណៈដែលសហព្រះរាជអាជ្ញាជាតិ មិនបានលើកឡើងនូវសំអាងហេតុអំពីផលវិបាកនោះ សហព្រះរាជអាជ្ញាអន្តរជាតិសន្មតថា លោកស្រីមានបំណងចង់លើកឡើងថា ការស៊ើបសួរជាឯកតោភាគីនេះ គឺធ្វើឱ្យបាត់ប្រសិទ្ធិភាពនៃសេចក្តីសន្និដ្ឋានថ្មីនេះ ដែលហេតុដូចនេះគួរតែត្រូវបានបដិសេធចោល។[១២]

១៣. សហព្រះរាជអាជ្ញាអន្តរជាតិបញ្ជាក់ឡើងវិញជាថ្មីថា អញ្ញត្រកម្មជាបឋមដែលសហព្រះរាជអាជ្ញាជាតិបានលើកឡើងអំពីបញ្ហានេះ គឺយឺតពេលជាទីបំផុត និងជាគំនិតដែលគិតឃើញតាមក្រោយ។ នៅក្នុងករណីណាក៏ដោយ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា និយ័តភាពនៃការស៊ើបសួរបឋម គឺមិនមានការជាប់ទាក់ទងគ្នាទៅនឹងការកំណត់សម្រេចអំពីដំណើរការនៃនីតិវិធីទាំងនេះទេ។ បញ្ហាតែមួយគត់ ដើម្បីកំណត់សម្រេចនៅទីនេះ គឺអំពីថាតើសេចក្តីសន្និដ្ឋានដាក់ជូនថ្មីគួរត្រូវបញ្ជូនទៅឱ្យសហចៅក្រមស៊ើបអង្កេតដែរឬទេ? បញ្ហាអំពីនិយ័តភាពនៃការស៊ើបសួរបឋម ទោះបីជាមានការជំទាស់ដែលមានសុពលភាពក្តី ក៏វាស្ថិតនៅក្នុងយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេត ដែលអាចអនុញ្ញាឱ្យភាគីដែលជាអ្នកដាក់សំណើនូវការដោះស្រាយតាមផ្លូវច្បាប់ ដោយការធ្វើមោឃភាពស្របតាមវិធាន៧៦ នៃ

---

[១១] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌទី៣។

[១២] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌទី១០ ។

វិធានផ្ទៃក្នុងដែរ។ អាស្រ័យហេតុនេះ ក្នុងដំណាក់កាលនេះ និងនៅក្នុងដំណើរការនៃនីតិវិធីនេះ អង្គបុរេជំនុំជម្រះមិនមានយុត្តាធិការនឹងធ្វើការពិនិត្យពិចារ ណាទៅលើអញ្ញត្រកម្មនេះទេ។[១៣]

១៤. វិសាលភាពនៃដំណើរការនីតិវិធីត្រូវបានកម្រិតត្រឹមតែបញ្ហា ដែលបានលើកឡើងនៅក្នុងសេចក្ដីថ្លែងការណ៍របស់អ្នកដែលស្នើសុំ (ដែលនៅទីនេះ គឺសហព្រះរាជអាជ្ញាអន្តរជាតិ) និងសេចក្ដីថ្លែងការណ៍ឆ្លើយតបដោយអ្នកឆ្លើយតប (ដែលនៅទីនេះ គឺសហព្រះរាជអាជ្ញាជាតិ)។ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា តុលាការអាជ្ញាកណ្ដាលកំណត់សម្រេចលើបញ្ហាផ្សេងៗ ដែលបានលើកឡើងនៅក្នុងសេចក្ដីថ្លែងការណ៍ និងក្លាយទៅជាតុលាការ ដែលលែងមានសិទ្ធិអំណាចតទៅទៀត (*functus officio*) ក្រោយពេលបានបំពេញភារកិច្ចរបស់ខ្លួនក្នុងការកំណត់សម្រេចរួចរាល់ហើយ។ ភាគីទាំងឡាយ ដែលលើកឡើងអំពីបញ្ហាថ្មីៗនៅមុនដំណាក់កាលដែលហួសពីវិសាលភាពនៃការខ្វែងយោបល់គ្នាពីដំបូង គឺត្រូវតែឆ្លងកាត់ការចាប់ផ្ដើមក្នុងកម្រិតខ្ពស់បំផុតមួយ ដើម្បីបានការទទួលយល់ព្រមទៅលើការលើកសំអាងទាំងនេះ ឬលើកឡើងនូវបញ្ហាទាំងនោះថា ជាការខ្វែងយោបល់គ្នាដែលទើបតែមានថ្មីៗ។ សហព្រះរាជអាជ្ញាអន្តរជាតិសង្កេតឃើញថា នៅទីនេះ សហព្រះរាជអាជ្ញាជាតិបានលើកឡើងនូវបញ្ហាផ្សេងៗដែលទើបតែមានថ្មីៗ នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងការចោទសួរដោយអង្គបុរេជំនុំជម្រះ ហើយមិនបានបង្ហាញអំពីមូលហេតុត្រឹមត្រូវថា តើហេតុអ្វីបានជាការលើកសំអាងថ្មីៗរបស់លោកស្រី ត្រូវយកមកដាក់ជំនួសឲ្យសេចក្ដីថ្លែងការណ៍ឆ្លើយតបរបស់លោកស្រី ដែលក្នុងនោះមិនបានលើកអំពីបញ្ហាទាំងនោះណាមួយទាល់តែសោះទៅវិញ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា ការលើកសំអាងថ្មីៗរបស់សហព្រះរាជអាជ្ញាជាតិគួរតែត្រូវបានបដិសេធចោល ឬក៏ធ្វើមិនដឹងមិនឮ។[១៤]

១៥. ដោយមិនធ្វើឲ្យខូចដល់អ្វីដែលមានពីមុនមកនេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមជូនជាសេចក្ដីសន្និដ្ឋានដើម្បីពិនិត្យពិចារណាថា និយ័តភាពនៃកិច្ចស៊ើបសួរបឋម ដែលនាំឲ្យមានការដាក់

---

[១៣] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌទី១១ ។

[១៤] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌទី១៣ ។

សេចក្តីសន្និដ្ឋានថ្មីៗទៀត គឺវាហួសពីវិសាលភាពនៃដំណើរការនៃនីតិវិធីនៃការខ្វែងយោបល់គ្នាទាំងនេះហើយ។[១៥]

១៦. ជាងនេះទៅទៀត គាត់លើកឡើងថា បញ្ហាអំពីនិយ័តភាពនៃសេចក្តីសន្និដ្ឋានជាបឋម គឺមិនមែនជាការតភ្ជាប់គ្នាទាំងស្រុង ដែលមិនអាចកាត់ផ្តាច់បានទៅនឹងបញ្ហាស្តីពីសេចក្តីសន្និដ្ឋានថ្មីៗ ដែលធ្វើឱ្យការកំណត់សម្រេចលើសេចក្តីសន្និដ្ឋានលើកទី២ អាចនឹងពឹងផ្អែកទៅលើការកំណត់សម្រេចទៅលើសេចក្តីសន្និដ្ឋានលើកទី១ នោះទេ។ បញ្ហាទាំងនេះ គឺជាបញ្ហាផ្សេងដាច់ពីគ្នា ដែលអាចដាក់ឱ្យស្ថិតនៅក្រោមការកំណត់សម្រេចដោយឯករាជ្យ។ ក្នុងករណីណាក៏ដោយ និយ័តភាពនៃបណ្តឹងណាមួយ នៅក្នុងអំឡុងពេលនៃការស៊ើបសួរអាចត្រូវបានតវ៉ាជំទាស់ដោយភាគីណាមួយផ្អែកតាមវិធាន ៧៦។ អាស្រ័យហេតុនេះ បើសិនជាភាគីណាមួយអាចលើកឡើងនូវករណីដែលមាន សុពលភាពថា ការស៊ើបសួរបឋមជា "ឯកតោភាគី" មួយដែលបានធ្វើឱ្យដំណើរការនៃនីតិវិធីបាត់បង់ប្រសិទ្ធិភាព ភាគីនោះអាចស្វែងរកសុំឱ្យធ្វើមោឃភាពនូវបណ្តឹងដែលលទ្ធផលណាមួយ ឬទាំងអស់។[១៦]

១៧. សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា ការអនុញ្ញាតដើម្បីឱ្យធ្វើការស៊ើបអង្កេតបឋមភាគច្រើននៅពេលដែលផ្តល់ដោយសហព្រះរាជអាជ្ញាតែមួយរូប ឬទាំងពីររូប គឺធ្វើឡើងដោយផ្ទាល់មាត់ ដែលច្បាប់ បានអនុញ្ញាតធ្វើបែបនេះបាន។ ក្នុងករណីណាក៏ដោយ ឯកសារជាមូលដ្ឋាននៃការបង្កើតតុលាការនេះបានគ្រោងទុក អំពីការធ្វើសកម្មភាពរួមគ្នាដោយសហព្រះរាជអាជ្ញាទាំងពីរ ដើម្បីបំពេញឱ្យសម្រេចនូវអាណត្តិរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិលើកអំណះអំណាងថា ឯកសារទាំងនោះក៏បានគ្រោងទុកផងដែរថា សហព្រះរាជអាជ្ញាត្រូវអនុវត្តមុខងារប្រចាំថ្ងៃរបស់ខ្លួនដោយរួមគ្នា ឬដាច់ដោយឡែកពីគ្នា។ អាស្រ័យហេតុនេះដោយសន្មតថា ការស៊ើបសួរបឋមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺជាការស៊ើបអង្កេតដែលជាក់ស្តែងធ្វើឡើងដោយ "ឯកតោភាគី" នោះក្តី ក៏ផ្អែកតាមវិធានផ្ទៃក្នុង គាត់លើកឡើង

---

[១៥] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌទី១៤ ។

[១៦] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌទី១៥ ។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

ទៀតថា គឺអាចអនុញ្ញាតឲ្យធ្វើបានដែរ ឲ្យតែការខ្វែងយោបល់គ្នានោះ ត្រូវបានធ្វើឲ្យបានឃើញច្បាស់លាស់ និងជាក់លាក់ នៅក្នុងដំណាក់កាលនៃការចុះហត្ថលេខាលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។[១៧]

១៨. យើងយល់ឃើញថា តាមរយៈការអះអាងរបស់សហព្រះរាជអាជ្ញាទាំងពីរ ពិតជាមិនឃើញមានការពិភាក្សា ឬ ការផ្តល់ព័ត៌មានណាមួយ ទាក់ទងទៅនឹងការស៊ើបអង្កេតបឋមរវាងសហព្រះរាជអាជ្ញាទាំងពីរ ដើម្បីឈានទៅដល់ការរៀបចំឲ្យមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ និងដីកាសន្និដ្ឋានញ្ជូនរឿងឲ្យស៊ើបសួរទី៣ នោះទេ។ ដូច្នេះ យើងយល់ឃើញថា ការស៊ើបអង្កេតបឋមគឺត្រូវបានធ្វើឡើង ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ដោយឯកឯង។ ទន្ទឹមនឹងនោះ ការសុំទោសរបស់លោក រ៉ូប៊ើត ភីធីត ព្រះរាជអាជ្ញារងអន្តរជាតិ ដែលពុំត្រូវបានសហព្រះរាជអាជ្ញាអន្តរជាតិបដិសេធនោះ ជាសក្ខីកម្មបញ្ជាក់កាន់តែច្បាស់ថែមទៀតថា ពិតជាមានការខកខាន ពុំបានជូនដំណឹងដល់សហព្រះរាជអាជ្ញាជាតិអំពីការស៊ើបអង្កេតបឋមប្រាកដមែន។

១៩. យោងតាមមាត្រា១៦ នៃច្បាប់ អ.វ.ត.ក និង មាត្រា ៦(១) នៃកិច្ចព្រមព្រៀង យើងយល់ឃើញថា ក្នុងករណីនៃការខ្វែងយោបល់គ្នានេះ ការស៊ើបអង្កេតបឋម ជាចំណុចផ្តើមមួយយ៉ាងសំខាន់ ដែលធ្វើឲ្យដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យសួរមានសុពលភាព។ ការដែលសហព្រះរាជ-អាជ្ញាអន្តរជាតិ បើកការស៊ើបអង្កេតបឋមដោយគ្មានការជូនដំណឹងជាមុន ឬ ការពិភាក្សាក្នុងការសហការគ្នាជាមួយសហព្រះរាជអាជ្ញាជាតិ គឺជាការរំលោភទៅលើច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង និង វិធានផ្ទៃក្នុង។ ផលវិបាកនៃការរំលោភខាងលើ អាចមានក្នុងដំណើរការនីតិវិធីនៅដំណាក់កាលក្រោយមកទៀត នឹងមិនត្រូវយកមកពិចារណា ពាក់ព័ន្ធនឹងករណីខ្វែងយោបល់ចំពោះមុខយើងឡើយ។

---

[១៧] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌទី១៦ ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

០០១/១៨-១១-២០០៨-អ.វ.ត.ក/អ.ប.ជ

## ខ. ភាពចាំបាច់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី

២០. មូលហេតុចំបងនៃការខ្វែងយោបល់គ្នា ទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ និងទី៣ គឺឈរនៅលើមូលដ្ឋាននៃអង្គហេតុនានា ដែលបង្កើតជាឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ១៩៧៩ ថាតើអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ លើកទី២ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ ដែលស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរ-ជាតិនោះ ជាអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរចុះ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ហើយឬនៅ?

២១. ដើម្បីឆ្លើយតបទៅនឹងសំណួរខាងលើ យើងត្រូវពិនិត្យមើលថា តើអង្គហេតុ និងបទល្មើសដែលត្រូវចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើក ទី២ និងទី៣ មាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី១ ដែលចៅក្រមស៊ើបអង្កេតកំពុងធ្វើការស៊ើប-សួរហើយឬនៅ?

២២. អង្គហេតុដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ មាន៖

[redacted]

២៣. បទល្មើសដែលត្រូវចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២គឺ៖



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

[redacted]

២៤. អង្គហេតុដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ នេះមាន៖

[redacted]

២៥. បទល្មើសដែលត្រូវចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ នេះគឺ៖

[redacted]



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

[redacted]

២៦. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ បានលើកយកអង្គហេតុទាំងមូលនៃឧក្រិដ្ឋកម្មកើតឡើងនៅលើទឹកដីកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ បណ្តាលឲ្យប្រជាជនស្លាប់ចំនួន ១.៧លាននាក់ ដល់ ២.២លាននាក់ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣ថ្មី, ៤, ៥, ៦, ៣៩ថ្មី នៃច្បាប់ អ.វ.ត.ក និង ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

អង្គហេតុដែលលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី១ មាន៖

[redacted]

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

០០១/១៨-១១-២០០៨-អ.វ.ត.ក/អ.ប.ជ

[redacted]

អង្គហេតុខាងលើបង្កើតបានជាបទចោទប្រកាន់ដូចខាងក្រោម ៖

[redacted]

២៧. តាមការពិនិត្យខាងលើនេះ យើងយល់ឃើញថា អង្គហេតុ និងបទល្មើសដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ និងទី៣ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ដែលស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិនោះ សុទ្ធតែជាអង្គហេតុ និងបទល្មើសដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០៧ រួចហើយ។

២៨. យើងពិនិត្យឃើញថា នៅក្នុងដំណាក់កាលស៊ើបអង្កេតសំណុំរឿង លេខ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស នេះ សហព្រះរាជអាជ្ញាបានចេញសេចក្តីសន្និដ្ឋានបន្ថែម ឬ សេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមចំនួនបីគឺ៖

- ឯកសារ D83 ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០៨ ស្តីពី "សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទិនទៅនឹង [redacted]" ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

- ឯកសារ D98/I ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨ ស្តីពី "ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះសហចៅក្រមស៊ើបអង្កេត ដែលស្នើសុំឱ្យបញ្ជាក់អំពីវិសាលភាពនៃកិច្ចស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា"
- ឯកសារ D146/3 ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ ស្តីពី "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម" ។

២៩. យើងនឹងពិនិត្យមើលបន្ថែមទៀតទៅលើអង្គហេតុ និងបទល្មើស ដែលត្រូវចោទប្រកាន់នៅក្នុងសេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹង ឯកសារទាំងបីខាងលើនេះ៖

ក. មណ្ឌលសន្តិសុខភូមិភាគឧត្តរ (ឯកសារ D83)៖ អង្គហេតុនានាទាក់ទងនឹងមណ្ឌលសន្តិសុខ [redacted] ត្រូវបានសហព្រះរាជអាជ្ញាទទួលស្គាល់ តាមដីកាសន្និដ្ឋានស្ពាដែលបានលើកឡើងក្នុងកថាខណ្ឌទី៤០ ស្តីពីសកម្មភាព [redacted] និងជាមួយកថាខណ្ឌទី៣៦ ដែលសហចៅក្រមស៊ើបអង្កេតបានធ្វើការស៊ើបអង្កេតលើ [redacted] ដូច្នេះ សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទិននឹង [redacted] ពុំមែនជាអង្គហេតុថ្មីទេ។ អង្គហេតុទាំងនោះ បង្កើតបាននូវបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់គឺ៖

[redacted]

បទឧក្រិដ្ឋទាំងនេះត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី១រួចហើយ។

 



ខ. ទាក់ទងនឹងឯកសារ D98/I សហព្រះរាជអាជ្ញាបានបញ្ជាក់ថា កិច្ចស៊ើបសួរដែលបានស្នើសុំគឺមិនកំរិតត្រឹមតែអង្គហេតុទាំងឡាយដូចបានកំណត់នៅក្នុងកថាខណ្ឌទី៣៧ ដល់កថាខណ្ឌ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងក្នុងកថាខណ្ឌទី៥ ដល់ កថាខណ្ឌទី២០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមប៉ុណ្ណោះទេ។ល។ ដូច្នេះយោងចំណុច "ក" ខាងលើ អង្គហេតុទាំងនេះបានបញ្ជាក់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី១ រួចហើយ។

គ. ទាក់ទងនឹងឯកសារ D146 គឺមានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនត្រូវបានអះអាងថា ខ្លួនត្រូវបានបង្ខំឲ្យរៀបការដោយអង្គការ និងត្រូវបានគម្រាមដល់អាយុជីវិត ប្រសិនបើខ្លួនមិនបានទំនាក់ទំនងផ្លូវភេទជាមួយស្វាមីរបស់ខ្លួន។[១៨] អង្គហេតុទាំងនេះពុំមែនជាអង្គហេតុថ្មីទេ ដោយសារអង្គហេតុទាំងនេះបានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី១ ពីកថាខណ្ឌទី៤៩ ដល់ ៧២ ហើយអង្គហេតុនេះត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ដែលក្នុងនោះមាន [redacted] ផងដែរ។

៣០. ដូច្នេះយើងយល់ឃើញថា អង្គហេតុ និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ និងទី៣ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ មាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី១ រួចហើយ។ អង្គហេតុ និងឧក្រិដ្ឋកម្មទាំងនោះ ក៏ត្រូវបានសហព្រះរាជអាជ្ញាទទួលស្គាល់ក្នុងដីកាសន្និដ្ឋានស្តាពរចាប់ពីកថាខណ្ឌទី១៥ ដល់កថាខណ្ឌទី៤៥ ផងដែរ ផ្ទុយនឹងការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងកថាខណ្ឌទី៤ នៃចម្លើយតបចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០០៩ ថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី១ ត្រូវកម្រិតត្រឹមតែបទឧក្រិដ្ឋ ដែលបានកំណត់ [redacted] នោះ។

[១៨] ទំព័រទី២ នៃឯកសារលេខ D146។

តាមការបកស្រាយខាងលើ យើងយល់ឃើញថា មិនមានហេតុផលអ្វីដែលអាចនាំឱ្យសហ-ព្រះរាជអាជ្ញាអន្តរជាតិចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ និងទី៣ នោះទេ ដោយហេតុថា សំណុំរឿងលេខ ០០២ ពុំទាន់បិទការស៊ើបអង្កេតនៅឡើយទេ គឺបច្ចុប្បន្នស្ថិតក្នុងការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត។ ដូច្នេះ យើងយល់ឃើញថា អំណះអំណាងដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាជាតិ មានលក្ខណៈគ្រប់គ្រាន់ ដើម្បីទប់ស្កាត់ការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ និង ទី៣។ ដោយពិចារណាលើការរកឃើញនេះ យើងយល់ឃើញថា វាជាការពុំចាំបាច់ទេ ដើម្បីផ្តល់មូលហេតុលើអំណះអំណាងផ្សេងៗទៀត ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាជាតិនោះ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០០៩

ន័យ ថុល
ចៅក្រម

ហួត វុទ្ធី
ចៅក្រម

០០១/១៨-១១-២០០៨-អវតក/អបជ

## យោបល់របស់ចៅក្រម LAHUIS និងចៅក្រម DOWNING

១. ពួកយើងកត់សម្គាល់ឃើញថា សេចក្តីសន្និដ្ឋានរបស់សហភាគារបស់យើងដែលថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី មិនត្រូវបញ្ជូនទៅសហចៅក្រមស៊ើបអង្កេតដើម្បីស៊ើបសួរតាមផ្លូវតុលាការ ផ្អែកលើការយល់ឃើញរបស់ពួកគាត់ទៅលើបញ្ហាទីមួយ និងទីបី ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាជាតិនោះទេ។ ហេតុនេះ ពួកយើងនឹងគូសបញ្ជាក់អំពីការយល់ឃើញរបស់ពួកយើងទៅលើបញ្ហាទាំងពីរនេះ។

### I. អនីត្យានុកូលភាពនៃកិច្ចស៊ើបសួរបឋម

២. ពួកយើងកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាជាតិមិនបានលើកឡើងនូវទឡ្ហីករណ៍ណាមួយពាក់ព័ន្ធនឹងអនីត្យានុកូលភាពនៃកិច្ចស៊ើបសួរបឋមនោះទេនៅក្នុងចម្លើយតបរបស់គាត់ទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលបានដាក់កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩។ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែម ដោយស្នើឲ្យសហព្រះរាជអាជ្ញាផ្តល់ព័ត៌មានបន្ថែមទាក់ទិននឹងសមិទានភាព ដែលនៅពីក្រោយសេចក្តីសម្រេចរបស់ពួកគាត់ក្នុងការចោទប្រកាន់ជនជាប់សង្ស័យថ្មីៗ ឬក្នុងការប្រឆាំងនឹងការចោទប្រកាន់បែបនេះ និងដើម្បីឲ្យដឹងថាតើពួកគាត់បានធ្វើការអភិវឌ្ឍគោលនយោបាយស្តីពីការចោទប្រកាន់នៅក្នុងការអនុវត្តន៍ ឬជាលាយលក្ខណ៍អក្សរ។ នៅក្នុងការឆ្លើយតបទៅនឹងសេចក្តីណែនាំទាំងនេះ សហព្រះរាជអាជ្ញាជាតិបានលើកឡើងថា កិច្ចស៊ើបសួរបឋមត្រូវបានធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិដោយគ្មានការដឹងឮ និងការយល់ព្រមពីរូបគាត់ឡើយ[១]។ កិច្ចស៊ើបសួរបឋមដែលធ្វើឡើងដោយឯកឯងដោយសហព្រះរាជអាជ្ញាណាម្នាក់ដែលនាំឲ្យចេញនូវដីកាសន្និដ្ឋានថ្មីនោះ បាន

---

[១] សារណាតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី១៩។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី២២ ដល់២៥។

រំលោភលើច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ដូច្នេះហើយតាមការយល់ឃើញរបស់សហព្រះរាជអាជ្ញាជាតិ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីត្រូវតែធ្វើការបដិសេធចោល[២]។

៣. មាត្រា៦(៤) នៃកិច្ចព្រមព្រៀងចែងថា សហព្រះរាជអាជ្ញាត្រូវសហការគ្នាដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការចោទប្រកាន់។ ដូចដែលបានពិភាក្សានៅក្នុងកថាខណ្ឌទី១៦ នៃសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ព្រះរាជអាជ្ញាមួយរូបក្នុងចំណោមសហព្រះរាជអាជ្ញាទាំងពីររូប អាចបំពេញមុខងាររបស់ខ្លួន ដោយមិនចាំបាច់មានការយល់ព្រមពីព្រះរាជអាជ្ញាម្ខាងទៀត ប្រសិនបើគ្មានព្រះរាជអាជ្ញាណាមួយក្នុងចំណោមព្រះរាជអាជ្ញាទាំងពីររូប លើកឡើងឱ្យដោះស្រាយនូវការខ្វែងគំនិតគ្នាចំពោះមុខអង្គបុរេជំនុំជម្រះ នៅក្នុងរយៈពេលសាមសិបថ្ងៃទេនោះ។ នៅពេលការខ្វែងគំនិតគ្នាបានបញ្ជូនមកដល់អង្គបុរេជំនុំជម្រះ សហព្រះរាជអាជ្ញាមួយរូបអាចនៅតែបន្តចំណាត់ការ ដែលកំពុងរង់ចាំសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ លើកលែងតែមានពាក់ព័ន្ធនឹងចំណុចមួយក្នុងចំណុចនានាដែលមានចែងនៅក្នុងវិធាន ៧១(៣) នៃវិធានផ្ទៃក្នុង។ អនុលោមតាមវិធាន ៥០(១) នៃវិធានផ្ទៃក្នុង ការស៊ើបអង្កេតបឋមមិនមែនជាបញ្ហាមួយក្នុងចំណោមបញ្ហាទាំងនេះទេ។

៤. គេបានកត់សម្គាល់ឃើញថា អង្គហេតុពាក់ព័ន្ធនឹងការដឹកនាំកិច្ចស៊ើបសួរបឋមត្រូវបានសហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងផ្សេងទៅវិញ[៣]។ ទោះជាបែបណាក៏ដោយ ពួកយើងសង្កេតឃើញថា ផ្អែកលើអំណះអំណាងផ្ទាល់ខ្លួន សហព្រះរាជអាជ្ញាជាតិបានដឹងពីដំបូងអំពីការស៊ើបអង្កេតបឋមដែលធ្វើឡើងដោយអនុលោមតាមវិធាន៥០(១) នៅពេលមានកិច្ចប្រជុំធ្វើឡើងនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ដើម្បីពិភាក្សាការដាក់ដីកាសន្និដ្ឋានថ្មី ដូចមានចែងនៅក្នុងកថាខណ្ឌ១ នៃចម្លើយតបរបស់គាត់។ មួយវិញទៀត លោកស្រីបានទទួលការរៀបរាប់អំពីបញ្ហានេះកាន់តែច្បាស់នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៨ នៅពេលសហព្រះរាជអាជ្ញាអន្តរជាតិបាន

---

[២] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី២០។

[៣] សារណាតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី៥០ ដល់៥៥។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី១៦។

យោបល់របស់ចៅក្រម LAHUIS និងចៅក្រម DOWNING

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ជូនដំណឹងអំពីឯកសារអំណះអំណាងរបស់ខ្លួនតាមរយៈប្រព័ន្ធ អ.វ.ត.ក។ ដោយពិចារណាឃើញថា បញ្ហានេះសហព្រះរាជអាជ្ញាជាតិបានលើកឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះកាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ នៅក្នុងចម្លើយតបរបស់លោកស្រីទៅនឹងសេចក្ដីបង្គាប់របស់អង្គបុរេជំនុំជម្រះ ដែលជាចម្លើយទៅនឹងសំណួរអំពីលក្ខណៈខុសប្លែកគ្នានោះ ពួកយើងយល់ឃើញថា ទឡ្ហីករណ៍នេះមិនអាចយកទៅពិចារណាថាជាផ្នែកនៃការខ្វែងយោបល់គ្នាដែលអង្គបុរេជំនុំជម្រះបានទទួលនោះទេ។ អង្គហេតុដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាជាតិនេះមិនអាចយកទៅពិចារណាថា ជាអ្វីផ្សេងក្រៅពីពត៌មានជាមូលដ្ឋានដែលពាក់ព័ន្ធនោះទេ។ ដោយសារតែការសន្និដ្ឋាននេះ ត្រូវបានធ្វើឡើងដោយផ្អែកលើអំណះអំណាងរបស់ព្រះរាជអាជ្ញាជាតិខ្លួនឯងនោះ ដូច្នេះការពិភាក្សាថាតើលោកស្រីបានដឹង ឬមិនបានដឹងអំពីបញ្ហាការអនុវត្តន៍កិច្ចស៊ើបសួរបឋម មិនមានភាពចាំបាច់នោះទេ។

## II. ភាពចាំបាច់នៃដីកាសន្និដ្ឋានថ្មី

៥. អនុលោមតាមច្បាប់ អ.វ.ត.ក សហព្រះរាជអាជ្ញា "ទទួលបន្ទុកធ្វើការចោទប្រកាន់" នៅពេលសហចៅក្រមស៊ើបអង្កេត "ទទួលបន្ទុកធ្វើការស៊ើបអង្កេត"[៤]។ តាមរយៈការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម សហព្រះរាជអាជ្ញាបានកំណត់សម្រេចអំពីវិសាលភាពនៃការស៊ើបសួរតាមផ្លូវតុលាការ ដូចមានចែងនៅក្នុងវិធាន៥៣ និងវិធាន៥៥(២) និង(៣) នៃវិធានផ្ទៃក្នុង។

៦. យោងតាមសន្ទានុក្រមរបស់វិធានផ្ទៃក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ "សំដៅទៅលើដីកាជាលាយលក្ខណ៍អក្សរ ដែលចេញដោយសហព្រះរាជអាជ្ញា ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបើកការស៊ើបសួរចំពោះករណីបទល្មើសណាមួយ និងធ្វើការចោទប្រកាន់។" អនុលោមតាមវិធានផ្ទៃក្នុងទី៥៣(១) និង (៣) ដើម្បីចាត់ទុកថាមានសុពលភាព ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ត្រូវមានព័ត៌មានដូចខាងក្រោម៖

---

[៤] កិច្ចព្រមព្រៀង មាត្រា៥ និងមាត្រា៦។

“ក-សេចក្តីសង្ខេបអំពីអង្គហេតុ

ខ-ប្រភេទនៃបទល្មើសដែលត្រូវចោទប្រកាន់

គ-បទប្បញ្ញត្តិច្បាប់ដែលមានកំណត់ និងបង្ក្រាបបទឧក្រិដ្ឋនេះ

ឃ-ឈ្មោះរបស់បុគ្គលដែលត្រូវធ្វើការស៊ើបអង្កេត ប្រសិនបើមាន

ង-កាលបរិច្ឆេទ និងហត្ថលេខារបស់សហព្រះរាជអាជ្ញាទាំងពីរ”។

៧. អង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម បានកំណត់អំពីវិសាលភាពនៃការស៊ើបអង្កេតតាមផ្លូវតុលាការដូចដែលបានគូសបញ្ជាក់ដោយអង្គបុរេជំនុំជម្រះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ (“សេចក្តីសម្រេចលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឌុច”[៥]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម គឺយោងទៅលើអង្គហេតុច្បាស់លាស់ ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋចោទប្រកាន់ ប្រភេទបទល្មើស ដែលនាំឲ្យសហព្រះរាជអាជ្ញាមានមូលហេតុជឿជាក់ថា បទល្មើសទាំងនេះបានប្រព្រឹត្តស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ ដីកាសន្និដ្ឋាននេះ ត្រូវតែមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ និងចែងអំពីអំពើឧក្រិដ្ឋច្បាស់លាស់ ដែលកំណត់នូវពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តបទល្មើស[៦]។

៨. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលមានលក្ខណៈទូលំទូលាយ ដែលអាចរួមបញ្ចូលនូវបទល្មើសទាំងអស់ដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក ដែលបានប្រព្រឹត្តនៅក្នុង

---

[៥] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស (អ.ប.ជ០២), កាំង ហ្គេកអ៊ាវ ហៅ “ឌុច”, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី កាំង ហ្គេកអ៊ាវ ហៅ “ឌុច” ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨, D99/3/42 (“សេចក្តីសម្រេចលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឌុច”) កថាខណ្ឌ៣៥-៣៩, ៤៤ និង១២៥។

[៦] ប្រព័ន្ធច្បាប់បារាំង ដែលច្បាប់កម្ពុជាភាគច្រើនផ្អែកលើ ត្រូវបានប្រើប្រាស់ដើម្បីជួយអង្គបុរេជំនុំជម្រះក្នុងការបកស្រាយវិធានផ្ទៃក្នុង ជាពិសេសជាងនេះគឺសំអាងដូចតទៅនេះ៖ Crim. Cass., 93-84843, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៤ (មិនបានផ្សព្វផ្សាយ)។ C. Guéry, *Instruction préparatoire*, Rép. Pén. Dolloz, ខែមករា ឆ្នាំ២០០៨ កថាខណ្ឌ ៩៧។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ប្រទេសកម្ពុជា នៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដោយគ្មានសំអាងទៅនឹងស្ថានភាពអង្គហេតុច្បាស់លាស់នោះ នឹងមិនមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ក្នុងការបំពេញលក្ខខណ្ឌតម្រូវរបស់វិធាន៥៣(១) នៃវិធានផ្ទៃក្នុងនោះទេ។

៩. ក្នុងការអនុវត្តន៍គោលការណ៍ដែលមានចែងខាងលើ សហព្រះរាជអាជ្ញាលើកឡើងយ៉ាងច្បាស់នៅក្នុងកថាខណ្ឌទី១២២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីមួយថា សហព្រះរាជអាជ្ញាបានសម្រេច "បើកការស៊ើបសួរលើជនសង្ស័យឈ្មោះ នួន ជា, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ និង កាំង ហ្គេចអ៊ាវ (ឌុច) ទៅលើអង្គហេតុទាំងឡាយដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌទី៣៧ ដល់ទី៧២"។ កថាខណ្ឌទី៣៧ ដល់ទី៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីមួយ បានចែងអំពីអំពើឧក្រិដ្ឋចំនួន២៥ ដែលបានកើតឡើងនៅទីកន្លែងផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជា ដែលអំពើឧក្រិដ្ឋទាំងនោះត្រូវបានកំណត់អត្តសញ្ញាណច្បាស់លាស់។ [redacted]។

១០. តាមរយៈដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានស្នើសុំសហព្រះរាជអាជ្ញាបំភ្លឺឲ្យបានច្បាស់អំពីដែនកំណត់នៃការស៊ើបសួរ "ថាតើការស៊ើបសួរ គួរតែរិតត្បិតចំពោះតែអង្គហេតុដែលមានបញ្ជាក់នៅក្នុងកថាខណ្ឌទី៣៧ ដល់ទី៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និង កថាខណ្ឌទី៥ ដល់ទី២០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមតែប៉ុណ្ណោះ ឬក៏ត្រូវតែពង្រីកទៅដល់គ្រប់អង្គហេតុទាំងអស់ ទោះបីជាអង្គហេតុនោះមានលើកឡើង ឬ មិនមានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមក៏ដោយ នៅពេលណាដែលអង្គហេតុទាំងអស់នោះអាចជួយដល់ការស៊ើបអង្កេតក្នុងការបង្ហាញថា ស្ថានភាពអង្គហេតុទាំងឡាយដែលមានបញ្ជាក់នៅក្នុងកថាខណ្ឌទាំងឡាយខាងលើ គឺជាបទឧក្រិដ្ឋដែលស្ថិត

នៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬ អាចជួយដល់ការស៊ើបអង្កេតអំពីការទទួលខុសត្រូវរបស់បុគ្គលណាមួយចំពោះឧក្រិដ្ឋកម្មបែបនេះនោះ”[៧]។

១១. សហព្រះរាជអាជ្ញាបានឆ្លើយតបដូចខាងក្រោមនេះ៖

> “សហព្រះរាជអាជ្ញា សូមធ្វើការបញ្ជាក់ថា កិច្ចស៊ើបសួរដែលបានស្នើសុំ គឺមិនកម្រិតត្រឹមតែអង្គហេតុទាំងឡាយដូចបានកំណត់ជាក់លាក់នៅក្នុងកថាខណ្ឌទី៣៧ ដល់កថាខណ្ឌទី៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងក្នុងកថាខណ្ឌទី៥ ដល់កថាខណ្ឌទី២០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមប៉ុណ្ណោះទេ កំប៉ុន្តែវាលាតសន្ធឹងដល់គ្រប់អង្គហេតុទាំងអស់ ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានទាំងពីរនេះទៀតផង *ឲ្យតែ* អង្គហេតុទាំងនេះជាជំនួយនៅក្នុងកិច្ចស៊ើបសួរ៖
>
> ក- ធាតុផ្សំយុត្តាធិការនានាដែលចាំបាច់ដើម្បីកំណត់ថាតើ ស្ថានភាពនៃអង្គហេតុនានាដូចមានចែងជាក់លាក់នៅក្នុងកថាខណ្ឌទី ៣៧ ដល់៧២ និងកថាខណ្ឌទី ៥ ដល់២០ រួមបង្កើតបានទៅជាបទឧក្រិដ្ឋផ្សេងៗដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរឬទេ? ឬ
>
> ខ- ទម្រង់នៃការទទួលខុសត្រូវរបស់ជនសង្ស័យទាំងឡាយ ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

១២. សហព្រះរាជអាជ្ញា បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមចំនួនពីរលើក ដើម្បីស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបសួរអង្គហេតុថ្មីដែលមិនបានគ្របដណ្តប់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបអង្កេតលើកទីមួយ[៨]។ វាមានតម្លៃក្នុងការកត់សម្គាល់ថា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម [redacted]

---

[៧] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨, D98។

[៨] សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា [redacted], ថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០០៨, D83។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងសេចក្តីសន្និដ្ឋានបន្ថែម ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩, D146/3 (“សេចក្តីសន្និដ្ឋានបន្ថែមលើកទីពីរ”)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C. * C.E.T.C. *

[redacted] (“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីមួយ” សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា៖

> “មានអង្គហេតុថ្មីៗត្រូវបានបញ្ជូនមកកាន់សហព្រះរាជអាជ្ញា ដោយសហចៅក្រមស៊ើបអង្កេតតាមរយៈដីកាបញ្ជូនរឿងទៅពិនិត្យរបស់ខ្លួន ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២00៨ ដោយស្នើឲ្យសហព្រះរាជអាជ្ញាផ្តល់យោបល់ថា តើសហចៅក្រមស៊ើបអង្កេតគួរតែបើកការស៊ើបសួរទៅលើខ្លឹមសារនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឬក៏អត់ [redacted]។ សហព្រះរាជអាជ្ញាសូមស្នើថា ទីតាំងនៃបទឧក្រិដ្ឋនេះក្លាយទៅជាផ្នែកនៃសំណុំរឿង ដែលបានទឹងកំពុងធ្វើការស៊ើបសួរដោយសហចៅក្រមស៊ើបអង្កេត គឺសំណុំរឿងលេខ៖ 00២/១៩-0៩-២00៧/អ.វ.ត.ក/ក.ស.ច.ស”។

១៣. ពួកយើងយល់ឃើញថា ឯកសារទាំងនេះ ដែលបានដាក់រួមគ្នាដោយសហព្រះរាជអាជ្ញាទាំងពីរ បានបង្ហាញយ៉ាងច្បាស់ថា ការស៊ើបអង្កេតតាមផ្លូវតុលាការនៅក្នុងសំណុំរឿងលេខ 00២/១៩-0៩-២00៧-អវតក/កសចស បានគ្របដណ្តប់តែស្ថានភាពអង្គហេតុដែលមានចែងនៅក្នុងកថាខណ្ឌ ៣៧ ដល់ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបអង្កេតលើកទីមួយ, កថាខណ្ឌ ៥ ដល់ ២0 នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីមួយ និងកថាខណ្ឌ ២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីពីរប៉ុណ្ណោះ (“អង្គហេតុដែលស្ថិតក្រោមការស៊ើបអង្កេត”)។ ប្រសិនបើ “អង្គហេតុនៃបទល្មើសទាំងអស់ដែលបានកើតឡើងនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ” ត្រូវបានរួមបញ្ចូលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីមួយ ដូចដែលបានអះអាងដោយព្រះរាជអាជ្ញាជាតិ[៥] ដូច្នេះសហចៅក្រមស៊ើបអង្កេតមិនចាំបាច់ចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ឬក៏សហព្រះរាជអាជ្ញាមិនចាំបាច់ដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនោះទេ។ តាមការយល់ឃើញរបស់យើង គោលជំហររបស់ព្រះរាជអាជ្ញាជាតិ គឺមិនស៊ីសង្វាក់គ្នាជាមួយនិងការអនុវត្តន៍កាលពីមុនដែល

[៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌទី៥១។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

អនុម័តរួមគ្នាដោយសហព្រះរាជអាជ្ញាទាំងពីរ មិនស៊ីសង្វាក់គ្នាជាមួយនឹងច្បាប់ អ.វ.ត.ក ព្រមទាំងវិធានផ្ទៃក្នុងនោះទេ។

១៤. ពួកយើងបានកត់សម្គាល់បន្ថែមថា ទឡ្ហីករណ៍ដែលលើកឡើងដោយព្រះរាជអាជ្ញាជាតិ ដូចមានចែងនៅក្នុងកថាខណ្ឌទី៥០ និងទី៥១ នៃចម្លើយតបរបស់លោកស្រីទៅនឹងឯកសារអំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទឡ្ហីករណ៍នេះផ្អែកលើភាពមិនច្បាស់លាស់រវាងប្រភេទបទល្មើសនៃអំពើឧក្រិដ្ឋ និងអង្គហេតុពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋដែលបានបញ្ជូនទៅស៊ើបអង្កេត។ នៅពេលប្រភេទបទល្មើសដែលស្នើឡើងដោយសហព្រះរាជអាជ្ញា ផ្តល់ការណែនាំដល់សហចៅក្រមស៊ើបអង្កេត ឲ្យយល់ដឹងអំពីវិសាលភាពនៃការស៊ើបសួររបស់ខ្លួននោះ[១០] វិសាលភាពនៃការស៊ើបសួរខ្លួនឯងនេះត្រូវបានកំណត់សម្រេចតាមរយៈអង្គហេតុច្បាស់លាស់ពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដូចដែលបានរៀបរាប់ខាងលើ។

១៥. ដោយបានកំណត់អត្តសញ្ញាណអង្គហេតុ ដែលស្ថិតក្រោមការស៊ើបអង្កេតបច្ចុប្បន្ននេះ ពួកយើងនឹងពិនិត្យមើលថាតើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី ត្រូវបានគ្របដណ្តប់ ឬមិនត្រូវបានគ្របដណ្តប់ដោយកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការនៅក្នុងសំណុំរឿងលេខ០០២។

១៦. គេបានកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិបានប្រកាសថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីកើតមកពីកិច្ចស៊ើបសួរបឋមដែលធ្វើដោយការិយាល័យសហព្រះរាជអាជ្ញាជាគោលការណ៍ឈរលើមូលដ្ឋាននៃការវិភាគឯកសារនានា ដែលមានស្រាប់នៅឃ្លាំងកន្លែងដែលប្រមូលបានតាំងពីមុនថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ជាដើម នៅមុនពេលដាក់ដីកា

[១០] សេចក្តីសម្រេចលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឌុច កថាខណ្ឌទី៣៥។

សន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី១[១១]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីទាំងនេះ មិនកើតមានឡើងដោយសារដីកាបញ្ជូនពីសហចៅក្រមស៊ើបសួរនោះទេ។

១៧. ពួកយើងសង្កេតឃើញថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីមួយ ទីពីរ និងទីបី ត្រូវបានរៀបចំឡើងខុសប្លែកពីគ្នា ដោយសារតែដីកាទាំងនោះសំដៅទៅលើការទទួលខុសត្រូវរបស់ជនជាប់សង្ស័យផ្សេងៗគ្នា។

- ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីមួយ ត្រូវបានរៀបចំឡើងយោងតាម<u>ប្រភេទនៃបទល្មើសតាមផ្លូវច្បាប់</u>ដែលត្រូវបានធ្វើឡើង។ គេបានកំណត់អត្តសញ្ញាណចំពោះបទល្មើសតាមផ្លូវច្បាប់នីមួយៗ ទីកន្លែងប្រព្រឹត្តបទល្មើសជាក់លាក់ដែលស្ថិតនៅទូទាំងប្រទេស។ វាត្រូវបានបំពេញតាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួរទីមួយដែលគ្របដណ្តប់យ៉ាងជាក់លាក់ទៅលើបទឧក្រិដ្ឋ ដែលបានលើកឡើងថា [redacted] និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរ ដែល [redacted]។

- ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរ ត្រូវបានរៀបចំឡើងដោយយោងតាម [redacted] ដែលនៅក្នុងនោះអំពើឧក្រិដ្ឋដែលបានចោទប្រកាន់បានកើតមានឡើង។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរ គ្របដណ្តប់ផ្តាច់មុខទៅលើ [redacted]។

---

[១១] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី៥០ ដល់៥៥។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំ កថាខណ្ឌទី១៦។

- ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីបី ត្រូវបានរៀបចំឡើងយោងតាមទីតាំងដែលបានគ្របដណ្ដប់ទៅលើទី[redacted]។

១៨. ពួកយើងកត់សម្គាល់ឃើញថា គេបានបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរថា ដីកាសន្និដ្ឋាននេះមានអង្គហេតុទាំងពីរជាន់គ្នានឹងអង្គហេតុនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីមួយ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទីមួយ ព្រមទាំងអង្គហេតុថ្មី ដែលបច្ចុប្បន្ននេះមិនមែនជាផ្នែកនៃកិច្ចស៊ើបសួរនោះទេ:

"៥. សំណើនេះទាក់ទិននៅនឹងការចូលរួមរបស់ជនជាប់ចោទនៅក្នុងអំពើឧក្រិដ្ឋទាំងពីរ ដែលបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២00៧ (ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី១) ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២00៨ និងអំពើឧក្រិដ្ឋជាក់លាក់ផ្សេងទៀតដែលមិនបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានមុនៗ។ ឧក្រិដ្ឋកម្មទាំងឡាយដែលបានរួមបញ្ចូលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២នេះ ដែលជាន់គ្នានឹងឧក្រិដ្ឋកម្មនានាដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកមុន និងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម គឺបានកើតឡើងនៅក្នុងទីកន្លែងផ្សេងៗដូចមានខាងក្រោម:

១) [redacted]។
២) [redacted]។
៣) [redacted]។
៤) [redacted]។
៥) [redacted]។
៦) [redacted]។ និង
៧) [redacted]។

៦. ឧក្រិដ្ឋកម្មដែលស្ថិតនៅក្រៅដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី១ និងដីកាសន្និដ្ឋាន



* អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

បញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម បានកើតឡើងនៅទីកន្លែងនានាដូចខាងក្រោម:

១) [redacted]។
២) [redacted]។
៣) [redacted]។
៤) [redacted]។
៥) [redacted]។ និង
៦) [redacted]។

១៩. បន្ទាប់ពីបានប្រៀបធៀបដីកាសន្និដ្ឋានទាំងពីររួចមក ពួកយើងយល់ឃើញថា អំណះអំណាងជាលាយលក្ខណ៍អក្សរនេះ បានពណ៌នាយ៉ាងច្បាស់លាស់អំពីទំនាក់ទំនងរវាងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីមួយ។

២០. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី ក៏បានកំណត់អត្តសញ្ញាណទីកន្លែងឧក្រិដ្ឋកម្មចំនួនពីរកន្លែងផងដែរដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីមួយ:

"[redacted]"[១២]។

"[redacted]"[១៣]។

---

[១២] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី កឋាខណ្ឌទី៧៣។
[១៣] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី កឋាខណ្ឌទី៧៨។



PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRÉLIMINAIRE

បន្ថែមពីលើទីកន្លែងឧក្រិដ្ឋកម្មទាំងពីរនេះ ពួកយើងកត់សម្គាល់ឃើញថា ការសម្លាប់នៅមណ្ឌលសន្តិសុខវត្តគីរីរម្យ ភូមិភាគពាយ័ព្យ ជាន់គ្នាទៅនឹងការសម្លាប់ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះទីមួយ យ៉ាងហោចណាស់ក៏ទៅលើវិសាលភាពខ្លះដែរ[១៤]។

២១. ពួកយើងកត់សម្គាល់ឃើញថា ទីកន្លែងឧក្រិដ្ឋកម្មផ្សេងទៀតដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះទីបី មិនពាក់ព័ន្ធទៅនឹងទីកន្លែងដែលបានកំណត់អត្តសញ្ញាណនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះទីមួយនោះទេ ដែលរួមមាន:

(១) [redacted]។

(២) [redacted]។

(៣) [redacted]។

(៤) [redacted]។

[១៤] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីមួយ កថាខណ្ឌទី៦៨។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីបី កថាខណ្ឌទី៦០។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

២២. បន្ទាប់ពីបានប្រៀបធៀបដីកាសន្និដ្ឋានថ្មីនេះ ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី មួយ ព្រមទាំងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរួចមក ពួកយើងសន្និដ្ឋានថា ដីកាសន្និដ្ឋានថ្មីគ្របដណ្តប់ទៅលើអង្គហេតុថ្មីទាំងពីរ ក៏ដូចជាអង្គហេតុនានាដែលជាន់គ្នា ជាមួយនឹងអង្គហេតុដែលគ្របដណ្តប់ក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ នៅក្នុងសំណុំរឿងលេខ ០០២។ អនុលោមតាមវិធានផ្ទៃក្នុង ៥៥(២) អង្គហេតុថ្មីទាំងនេះមិនអាចធ្វើការស៊ើបសួរ ដោយសហចៅក្រមស៊ើបសួរឡើយ លុះត្រាតែដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី ឬដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមត្រូវបានដាក់ជូនដោយសហព្រះរាជអាជ្ញា។

២៣. គេសង្កេតឃើញថា វិធាន ៥៣(១) នៃវិធានផ្ទៃក្នុង ចែងថា "ប្រសិនបើសហព្រះរាជអាជ្ញា មានហេតុផលដែលនាំឱ្យជឿបានថា ឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំ ជម្រះវិសាមញ្ញត្រូវបានប្រព្រឹត្តឡើងនោះ ពួកគាត់ត្រូវបើកកិច្ចស៊ើបសួរមួយ"។ ផ្ទុយទៅវិញ វិធាន ៥០(១) នៃវិធានផ្ទៃក្នុងចែងថា "សហព្រះរាជអាជ្ញាអាចដឹកនាំកិច្ចស៊ើបសួរបឋម ដើម្បីកំណត់សម្រេចថា តើភស្តុតាងនានាបង្ហាញថាឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្រោមយុត្តា-ធិការនៃអង្គជំនុំជម្រះវិសាមញ្ញត្រូវបានប្រព្រឹត្តឡើងដែរឬទេ"។ វិធាន ៥៣(១) នៃវិធានផ្ទៃក្នុង ប្រើពាក្យ "ត្រូវតែ" ដែលមានលក្ខណៈជាកាតព្វកិច្ច ដែលផ្ទុយនឹងពាក្យ "អាច" ដែលមាន លក្ខណៈជាឆន្ទានុសិទ្ធិ ដូចបានឃើញនៅក្នុងវិធាន ៥០(១) នៃវិធានផ្ទៃក្នុង។ ចំពោះបទបញ្ញត្តិ ទាំងនេះ ពួកយើងមានគំនិតថា អនុលោមតាមវិធាន ៥៣(១) នៃវិធានផ្ទៃក្នុង ពុំមានអំណាច ឆន្ទានុសិទ្ធិដែលសហព្រះរាជអាជ្ញាត្រូវយកទៅអនុវត្តនោះទេ ដែលផ្ទុយទៅនឹងអ្វីដែលបាន សហព្រះរាជអាជ្ញាជាតិបានលើកឡើង។ នៅពេលណាដែលមានការទាញសេចក្តីសន្និដ្ឋានថា មាន "ហេតុផលដែលនាំឱ្យជឿបានថា ឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្រោមយុត្តាធិការនៃ អង្គជំនុំជម្រះវិសាមញ្ញត្រូវបានប្រព្រឹត្តឡើង" នោះ នៅពេលនោះ សហព្រះរាជអាជ្ញាមាន កាតព្វកិច្ចបើកកិច្ចស៊ើបសួរតាមរយៈការផ្ញើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

២៤. នៅក្នុងករណីនេះ សហព្រះរាជអាជ្ញាអន្តរជាតិ មានបំណងគ្របដណ្តប់លើការទទួលខុសត្រូវ របស់ជនជាប់សង្ស័យបន្ថែមទៀតចំពោះអង្គហេតុថ្មីៗផង និងចំពោះអង្គហេតុមួយចំនួនដែល ជាន់គ្នាជាមួយនឹងអង្គហេតុដែលកំពុងស្ថិតក្រោមការស៊ើបសួរផង។ សហព្រះរាជអាជ្ញា

អន្តរជាតិ បានសម្រេចចិត្តដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី។ នៅពេលដែលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី មានអង្គហេតុមួយចំនួនជាន់គ្នាជាមួយនឹងការស៊ើបសួរដែលកំពុងធ្វើបន្តនោះ បញ្ហាចោទបានកើតមានឡើងពាក់ព័ន្ធនឹងចំណុចថាតើ សហព្រះរាជអាជ្ញាអន្តរជាតិអាចដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីបានឬទេ ឬក៏ថាតើគាត់ត្រូវបន្តធ្វើបន្តទៀតតាមរយៈការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែរឬទេ ខណៈពេលដែលសហចៅក្រមស៊ើបអង្កេតបានទទួលនូវបញ្ហានោះមួយផ្នែករួចទៅហើយនោះ។

២៥. អនុលោមតាមវិធានផ្ទៃក្នុង ៥៣(១) សហ ព្រះរាជអាជ្ញាត្រូវបើកកិច្ចស៊ើបសួរតាមរយៈការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមួយ ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌ ៦ ខាងលើ ប្រសិនបើ "ពួកគាត់មានហេតុផលដែលនាំឱ្យជឿបានថាឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញត្រូវបានប្រព្រឹត្តឡើង"។ ពុំមានលក្ខខណ្ឌនីតិវិធីផ្សេងទៀត ត្រូវបានគូសបញ្ជាក់នៅក្នុងវិធានផ្ទៃក្នុង ឬនៅក្នុងច្បាប់កម្ពុជាសម្រាប់ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ។

២៦. ពាក្យថា "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម" ត្រូវបានកំណត់ន័យនៅក្នុងសទ្ទានុក្រមនៃវិធានផ្ទៃក្នុងថាជា "ដីកាជាលាយលក្ខណ៍អក្សរដោយសហព្រះរាជអាជ្ញាដែលស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតឱ្យចេញដីកា ឬបំពេញកិច្ចបន្ថែមទៅលើការស៊ើបសួរដែលកំពុងបន្តធ្វើ"។ ពុំមានការបង្ហាញច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងលក្ខខណ្ឌសម្រាប់ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះទេ។ ក្នុងករណីដែលវិធានផ្ទៃក្នុង ៥៥(៣) បានស្នើថា សហព្រះរាជអាជ្ញាអាចដាក់បន្ថែមនូវអង្គហេតុថ្មីទៅក្នុងការស៊ើបសួរដែលកំពុងធ្វើបានតាមរយៈការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះ វិធានផ្ទៃក្នុងមិនបានរារាំងសហព្រះរាជអាជ្ញាមិនឱ្យជ្រើសរើសការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីនោះទេ[១៥]។ ពាក់ព័ន្ធនឹងបញ្ហានេះ ពួកយើងកត់សម្គាល់ឃើញថា ប្រយោគចុងក្រោយនៃវិធាន

---

[១៥] ប្រព័ន្ធបារាំងត្រូវបានប្រើដើម្បីបកស្រាយវិធានផ្ទៃក្នុង ជាពិសេសមាត្រា ៨០(៣) នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំងដែលចែងថា:



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

ផ្ទៃក្នុង៥៥(៣) ដែលបានចែងថា "កាលណាអង្គហេតុថ្មីនេះត្រូវបានបញ្ជូនទៅឱ្យសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតគ្មានអំណាចធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះបានឡើយ លុះត្រាតែទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញា" គឺគេមើលឃើញថា ជាការកម្រិតអំណាចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការគ្រប់ដណ្តប់លើវិសាលភាពនៃកិច្ចស៊ើបសួរលើអង្គហេតុថ្មីៗដោយឯករាជ្យ ជាជាងកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

២៧. ស្របជាមួយនឹងវិធានផ្ទៃក្នុង ៥៣(១), ៥៥(២) និង ៥៥(៣) ព្រមទាំងនិយមន័យដែលបានចែងនៅក្នុងសន្ទានុក្រមនោះ ពួកយើងយល់ឃើញថា នៅដំណាក់កាលនេះ ជម្រើសរវាងការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ត្រូវបានបន្សល់នូវអំណាចឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា។ នៅក្នុងរឿងក្តីនេះ ត្រង់ចំណុចដែលសហព្រះរាជអាជ្ញាអន្តរជាតិចង់បើកកិច្ចស៊ើបសួរទៅលើអង្គហេតុថ្មីទាំងពីរ និងអង្គ-

---

"មាត្រា ៨០(៣)៖
ក្នុងករណីដែលបទល្មើសមួយដែលមិនគ្រប់ដណ្តប់ដោយដីកាសន្និដ្ឋានចោទប្រកាន់ ត្រូវបាននាំយកទៅឱ្យចៅក្រមស៊ើបអង្កេតដឹងឮនោះ គាត់ត្រូវតែទំនាក់ទំនងភ្លាមទៅរដ្ឋអាជ្ញាស្រុកអំពីពាក្យបណ្តឹងឬកំណត់ហេតុផ្លូវការដែលមានអត្ថិភាព។ ពេលនោះរដ្ឋអាជ្ញាស្រុកអាចតម្រូវឱ្យចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេតអង្គហេតុបន្ថែមតាមរយៈដីកាសន្និដ្ឋានបន្ថែម ឬតម្រូវឱ្យគាត់បើកកិច្ចស៊ើបសួរដោយឡែក ឬផ្ញើរឿងក្តីនោះទៅតុលាការកាត់ទោស ឬបង្គាប់ឱ្យមានកិច្ចស៊ើបសួរ ឬសម្រេចបោះរឿងក្តីចោល ឬបន្តចាត់វិធានការណាមួយដែលបានចែងនៅក្នុងមាត្រា ៤១-១ ដល់ ៤១-៣ ឬបញ្ជូនពាក្យបណ្តឹង ឬរបាយការណ៍ផ្លូវការទៅកាន់រដ្ឋអាជ្ញាស្រុកដែលមានសមត្ថកិច្ចតាមដែនដី។ ប្រសិនបើរដ្ឋអាជ្ញាស្រុកត្រូវការបើកកិច្ចស៊ើបសួរដាច់ដោយឡែក ការងារនេះអាចត្រូវគេប្រគល់ឱ្យចៅក្រមស៊ើបអង្កេតដដែល ដែលត្រូវបានចាត់តាំងស្របតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ នៃមាត្រា ៨៣"។

គេបានកត់សម្គាល់ឃើញថា តុលាការកំពូលបារាំង យល់ឃើញថា ថ្វីបើមានការលើកឡើងរបស់ខ្លួនក្តី វាមិនមានភាពចាំបាច់ថា ដីកាបញ្ជូនត្រូវផ្ញើពីចៅក្រមស៊ើបអង្កេតសម្រាប់ភាពបណ្តោះអាសន្នក្នុងការប្តឹងនេះទេ៖ Crim. Cass.31 March 1987, Bull. Crim 1987, no. 149, p. 405; Crim. Cass. 27 June 2001, Bull. Crim. 2001, no. 163, p.512; C. GUÉRY, *Instruction préparatoire*, Rép. Pén. Dalloz, ខែមករា ឆ្នាំ២០០៨, កថាខណ្ឌទី៨២។

ហេតុដែលជាន់គ្នាជាមួយនឹងការស៊ើបសួរដែលកំពុងធ្វើ ដើម្បីគ្របដណ្តប់លើការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋរបស់ជនជាប់សង្ស័យថ្មីៗនោះ ពុំមានបទបញ្ញត្តិច្បាប់ណាមួយដែលគួររារាំងគាត់មិនឱ្យដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីនោះទេ ទោះមានទំហំប៉ុណ្ណាក៏ដោយ ទោះបីជាអង្គហេតុមួយចំនួនបាននឹងកំពុងស្ថិតក្រោមការស៊ើបអង្កេតនៅក្នុងករណីផ្សេងរួចហើយក៏ដោយ។

២៨. ពួកយើងនឹងបានដឹងមុនអំពីបញ្ហានានា ដែលរួមទាំងនៅក្នុងអង្គហេតុថ្មីផងដែរដែលសហព្រះរាជអាជ្ញាអន្តរជាតិចង់យកទៅធ្វើការស៊ើបអង្កេត នៅក្នុងកិច្ចស៊ើបសួរសំណុំរឿងលេខ ០០២។ ដោយហេតុថា សហចៅក្រមស៊ើបអង្កេតបានដឹកនាំកិច្ចស៊ើបសួរនៅក្នុងសំណុំរឿងលេខ០០២ អស់រយៈពេលជិត ២ឆ្នាំហើយ ដែលនៅក្នុងអំឡុងពេលនេះ ជនត្រូវចោទបួន (៤)រូប ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននោះ ការបន្ថែមអង្គហេតុថ្មីៗនៃវិសាលភាព ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី នឹងប្រថុយចំពោះការពន្យារពេលកិច្ចដំណើរការនីតិវិធី ហើយជាផលវិបាកអាចរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទដែលត្រូវទទួលបាននូវការកាត់សេចក្តីក្នុងរយៈពេលមួយសមស្រប។ គេបានកត់សម្គាល់ឃើញថែមទៀតថា ការរួមបញ្ចូលនូវជនជាប់សង្ស័យថ្មីៗនៅក្នុងការស៊ើបអង្កេតដែលបានបើកជិតពីរឆ្នាំ កន្លងទៅនោះ អាចរំលោភលើសិទ្ធិរបស់ជនជាប់សង្ស័យថ្មីៗ ដោយសារតែពួកគេនឹងមិនត្រូវបានផ្តល់ឱកាសក្នុងការចូលរួមឱ្យបានសកម្មនៅក្នុងកិច្ចដំណើរការស៊ើបអង្កេតពីមុននោះទេ។

២៩. ចំពោះបញ្ហាដែលអាចកើតមាន ដែលអាចលើកឡើងតាមរយៈការដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមថែមទៀត និងចំពោះបញ្ហានានាដែលគួរយកទៅធ្វើការពិចារណាដោយសហព្រះរាជអាជ្ញាអន្តរជាតិផងដែរនោះ ពួកយើងយល់ឃើញថា ហេតុផលដែលគាំទ្រដល់ទឡ្ហីករណ៍ដែលថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីមិនមានភាពចាំបាច់ដូចដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាជាតិនោះ មិនគ្រប់គ្រាន់ក្នុងការរាំងស្ទះការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីទៅសហចៅក្រមស៊ើបអង្កេតនោះទេ។

៣០. ចៅក្រមចំនួនបីរូបផ្សេងទៀតមានយោបល់ថា ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ថ្មីមិនមានភាពចាំបាច់ទេ។ តាមការយល់ឃើញរបស់ពួកគាត់ នេះជាហេតុផលមួយគ្រប់គ្រាន់ក្នុងការទប់ស្កាត់ដល់ការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី ពួកគាត់ពិចារណាឃើញថា មិនមានភាពចាំបាច់ក្នុងការជជែកពិភាក្សាគ្នា អំពីទឡ្ហីករណ៍ផ្សេងទៀតដែលលើកឡើងដោយសហព្រះរាជអាជ្ញាជាតិនោះទេ បន្ទាប់ពីបានពិចារណាអំពីគោលជំហររបស់ចៅក្រមទាំងបីរូបផ្សេងទៀតនេះ ការជជែកពិភាក្សាគ្នាដែលធ្វើឡើងរវាងចៅក្រមតែចំនួនពីររូប អំពីទឡ្ហីករណ៍ផ្សេងទៀតដែលលើកឡើងដោយសហព្រះរាជអាជ្ញាជាតិនោះ នឹងមិនមានប្រយោជន៍នោះទេ ដោយសារតែការជជែកពិភាក្សានេះ នឹងមិនអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះទទួលបាននូវការបោះឆ្នោតអំពីសេចក្ដីសម្រេចលើការខ្វែងយោបល់គ្នា បានសម្លេងភាគច្រើនបួនសម្លេងនោះទេ។

**ភ្នំពេញ, ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០៩**

**Rowan DOWNING**
**ចៅក្រម**

**Katinka LAHUIS**
**ចៅក្រម**